មកដល់គោលដៅ ឈប់នៅពីមុខភូមិគ្រឹះដែលឈរស្ដឹមស្ដៃ តែស្ងាត់ជ្រងំកណ្ដាលក្រោម ស្រមោលថ្ងៃអស្ដង្គត។

 វិទូចុះពីជំនិះចុចកណ្ដឹង មួយខណៈក្រោយទើបឃើញរូបពូសួសដែលជាអ្នកនៅយាមផ្ទះ ចេញមកបើកទ្វារ។

យល់វត្តមានអ្នកកំលោះភ្លាម គាត់បង្ហាញអាការត្រេកអរពោលអរកខិបកខុបៈ

-លោកក្មួយ?

វិទូយល់ថាតាមមើល គឺអ្នកបម្រើរូបនេះកំពុងបារម្ភនិងចង់បានដំណឹងពីភីណាអ្នកនាងតូច របស់គ្រប់គ្នាបានជាគាត់អរភើតពេលឃើញវត្តមានអ្នកកំលោះ។ អ្នកកំលោះពោលតបទៅ កាន់គាត់ដោយទឹកមុខស្មើៈ

-ខ្ញុំសុំជួបអ្នកបង! ពូជួយជម្រាបអ្នកបងផង!

ភាគទី១៥

អ្នកកំលោះបន្លឺបណ្ដើរ ឈានជើងដើរសំដៅចូលទៅខាងក្នុងផ្ទះបណ្ដើរ។ សំឡេងបុរស បោលមកវិញហាក់សោកស្ដាយៈ

-អ្នកស្រីទើបតែចេញមុននេះបន្ដិច!

-អញ្ចឹង? (វិទូតបដោយភ្ញាក់ផ្អើល) ហើយចុះម៉េចពូមិនបើកឡានជូន?

-អត់ទេ! គឺអ្នកស្រីបើកទៅខ្លួនឯង! អត់មានអ្នកណាចាំផ្ទះ!

រំពេចនោះអ្នកកំលោះនឹកឃើញដល់សម្ដីភីណា "គឺពួកគេគេងដូចស្លាប់! ខ្ញុំគោះទ្វារផង ស្រែកហៅផង អត់មានអ្នកកម្រើកទេ! ពូសួសវិញខ្ញុំដើរទៅបន្ទប់គាត់យកសោឡានក៏គាត់ មិនទាំងដឹងខ្លួនផង!"។

នាយប៉ូលិសវិទូងាកមកសួរបុរសចំណាស់ដែលនៅឈរគួរសមក្បែរកាយភ្លាមៈ

-ពូ! ចុះយប់ដែលភីណារបួសនោះ ពូអាល័យទៅណាបានជាមិនបើកឡានឲ្យនាង!

បុរសទីទើរ គាត់និយាយតបតិចៗៈ

-គឺពេលនោះយប់ជ្រៅពេក កណ្តាលអធ្រាត្រទៅហើយ! ពួកខ្ញុំនៅផ្ទះខាងក្រោយគេងលក់ទាំងអស់ តែអ្នកស្រីមានប្រសាសន៍ថាអ្នកនាងតូចចេញទៅក្រៅព្រោះមានពួកម៉ាកហៅទៅលេងក្លឹប!អ្នកស្រីឃាត់មិនបាន អ្នកនាងតូចចេសយកឡានចេញទៅខ្លួនឯង!

វិទូជ្រួញចិញ្ចើមពិចារណា អ្នកកំលោះសួរវិញមួយៗ៖

-សោឡានទាំងអស់នៅនឹងពូមែនទេ? ម៉េចក៏អ្នកនាងយកបាន?

បុរសនៅទីទើរតាមមើលគាត់ពិតជាលង់លក់ក្នុងដំណេកដូចដែលភីណានិយាយមែន វិទូសួរបន្ថែម៖

-អ្នកនាងរបស់ពូឧស្សាហ៍ចេញដើរលេងយប់ទេកន្លងមក! ខ្ញុំចង់និយាយថាមុនពេលមានរឿងកើតឡើង!

បុរសចំណាស់គ្រវីក្បាលភ្លាម៖

-អត់ទេលោកក្មួយ! អ្នកនាងតែងតែចូលផ្ទះមុនម៉ោង៧យប់! ទោះរវល់អីក៏ដោយ! បើមានចូលរួមហូបការគេ! គឺខ្ញុំជាអ្នកទៅតាមការពារអ្នកនាងដោយផ្ទាល់! យូរម្តងទេ!

វិទូញាក់ស្មា ធ្វើភ្នែកមមីគេឈានទៅរកផ្ទះធំបណ្តើរនិយាយបន្តបណ្តើរ៖

-ចុះពូអត់ចម្លែកទេអីដែលនៅយប់កើតរឿង! ភីណាស្រាប់តែចេះចេញទៅលេងក្លឹប?

បុរសឆ្លើយតតាក់តតុប៖

-អ្នកស្រីថា មុនហ្នឹងទាស់សម្តីគ្នាខ្លះៗបានជាអ្នកនាងតូចខឹងហើយចេញទៅក្រៅទាំងកណ្តាលអធ្រាត្រ!

វិទូនឹកឃើញដល់សកម្មភាពកាលពីព្រឹក។ នាងពិតជាមានទម្លាប់ខឹងតូងហើយចាកចេញពីផ្ទះមែនគ្រាន់តែខុសគ្នាត្រង់ថានាងជិះរ៉ឺម៉កព្រោះនេះជាពេលថ្ងៃ នាងមិនពិបាកហៅ តែពេលនោះយប់ជ្រៅ នាងមានតែបើកឡានចេញខ្លួនឯងអញ្ចឹងមែន។ ប៉ុន្តែចុះម៉េចក៏សម្តីនាងនិងអ្នកស្រីកុលាបខុសគ្នា?

"ភ្លៀងធ្លាក់យ៉ាងខ្លាំងតាំងតែពីព្រលប់រហូតដល់យប់ជ្រៅក៏នៅមិនទាន់រាំង....ពេលនោះស្រាប់តែ ឮនៅជាន់ខាងលើមានស្នូរជើងមនុស្ស ....ទាំងខ្ញុំ ទាំងអ្នកបងសុទ្ធសឹងភ័យតែ អ្នក

បងនាំខ្ញុំឡើងទៅជាន់ខាងលើរកមើល....ពេលឡើងទៅដល់ យើងទាំងពីរបានឮសំឡេងមនុស្សនិយាយគ្នាក្នុងបន្ទប់ដាក់វត្ថុបុរាណឯណោះ" នេះជាសម្ដីត្រួសៗរបស់គូដណ្ដឹងដែលអ្នកកំលោះនៅចាំបាន។

សរុបមកវិញគឺកាលពីយប់កើតរឿង ពួកអ្នកបម្រើគ្មានអ្នកណានៅក្នុងហេតុការណ៍ទេ ដូច្នេះគ្មានអ្នកណាអាចដឹងបានថារវាងនារីទាំងពីរនោះ អ្នកណាជាអ្នកនិយាយពិតឡើយ។ មធ្យោបាយមានតែមួយគត់គឺអង្កេតរកការពិតដោយខ្លួនឯង។

ប្រសិនបើលើកនេះអ្នកកំលោះអាចរកឃើញថាសម្ដីស្ត្រីនោះជាការពិត អញ្ចឹងច្បាស់ណាស់ភីណាប្រាកដជាស្រមើស្រមៃព្រោះនាងលេងថ្នាំហួសកម្រិត តែប្រសិនបើអ្នកស្រីកុលាបនិយាយមិនពិតវិញ អញ្ចឹងហេតុអ្វីគាត់ស្លាប់ហើយរស់វិញថែមទាំងប្រឌិតរឿងបំភាន់គេឯងទៀត?

នាយប៉ូលិសយើងឈានចូលមកដល់កណ្ដាលបន្ទប់ទទួលភ្ញៀវធំល្វឹង ដែលមានបើកភ្លើងភ្លឺចិញ្ចាចផង។ រឿងដែលគួរឲ្យសោកស្ដាយនោះគឺថាផ្ទៃបន្ទប់ដែលបានតាក់តែងរៀបចំយ៉ាងគាប់ភ្នែក បែរជាស្ងាត់ជ្រងំគួរឲ្យស្រងេះស្រងោចទៅវិញ។

អ្នកឈរសម្លឹងជុំវិញផ្ទៃបន្ទប់ដោយអារម្មណ៍តានតឹង គេហដ្ឋានដែលសម្លឹងទៅគួរឲ្យកក់ក្ដៅម៉េចក៏បែរជាកើតមានរឿងហេតុជាបន្តបន្ទាប់ស្មុគស្មាញដល់ម្លឹង? សូម្បីតែភីណាក៏ចាកចេញលែងព្រមរស់នៅដែរ ។

វិទូដៀងភ្នែកសម្លឹងទៅសាឡុងដែលនៅស្ងៀមឃើងក្បែរជណ្ដើរ។ សន្សឹមៗគេងើបមុខសម្លឹងទៅជាន់ខាងលើ រួចបន្ទាប់មកសម្លឹងកាំជណ្ដើរតាំងតែពីលើរហូតដល់ក្រោម។ សំឡេងភីណាលាន់មកសាជាថ្មី "ពេលដែរខ្ញុំបែរក្រោយទៅរកអ្នកបងគឺឃើញគាត់កំពុងដួលត្រឡប់ត្រឡិនចុះមកជាន់ខាងលើ ខ្ញុំឃើញផ្ទាល់នឹងភ្នែក អ្នកបងបោកទៅនឹងជើងសាឡុងយ៉ាងខ្លាំងហើយគាត់ដេកនៅស្ងៀមលែងកម្រើក ខ្ញុំចូលទៅជិតគាត់អង្រួនគាត់បន្ទាប់មកខ្ញុំដឹងថាលែងមានដង្ហើម គាត់ស្លាប់បាត់ទៅហើយ! គាត់ស្លាប់មែន!"

វិទូឈានជើងដើរយឺតៗតម្រង់ទៅកាន់ទីនោះ ទាំងពិចារណាស្ងាត់ក្នុងចិត្តដោយភ្នែកនៅមិនដកពីទីនោះនៅឡើយ ។ អ្នកសម្លឹងទៅសាឡុងដែលស្ថិតនៅចំពីមុខជណ្ដើរ ហើយគិតថា

យោងតាមស្ថានភាពផ្ទៃបន្ទប់បើអ្នកស្រីកុលាបពិតជាបានធ្លាក់ពីខាងលើតាមជណ្តើរនេះមែន គាត់ប្រាកដជាត្រូវបោកទង្គិចទៅនឹងសាឡុងចំពោះមុខនេះពិតណាស់។

អ្នកកំលោះដើរចូលទៅក្បែរសាឡុងមួយដែលនៅចំពីមុខជណ្តើរ។ បើមានមនុស្សធ្លាក់រមៀលមក ចង់មិនចង់ គឺប្រាកដជាទង្គិចនឹងសាឡុងមួយនេះមុនគេបង្អស់។ អ្នកដាក់បង្គុយចុះប្រើភ្នែកសម្លឹងទៅកាន់សាឡុងដោយពិនិត្យពិច័យ ហើយលូកដៃទៅស្ទាប់ជ្រុងមួយ ដែលអ្នកដឹងថាមានស្នាមរបកច្បាស់ណាស់។

អ្នកកំលោះដៀងភ្នែករិះគិត តើស្លាកស្នាមនេះដឹងដែលធ្វើឲ្យភីណាជឿថា រឿងហេតុកាលពីរាត្រីនោះគឺជាការពិត តែបើសិនពិតជាដូចសម្តីភីណាថាអ្នកស្រីជាបងថ្លៃបានធ្លាក់តាមជណ្តើរពីជាន់ខាងលើមកទង្គិចនឹងសាឡុងត្រង់នេះមែន ម្ល៉េះសមកម្លាំងទង្គិចនោះខ្លាំងក្លាយ៉ាងណាទៅ បានជាបន្សល់ស្លាកស្នាមរបកយ៉ាងនេះ? បើដូច្នោះមែនកុំថាឡើយមនុស្ស សូម្បីតែដែកថែបក៏ប្រាកដជាត្រូវប្រែរូបរាងខុសពីដើមដែរទម្រាំតែបងថ្លៃនាងដែលគ្រាន់តែជាស្រីម្នាក់នោះ?

វិទូក្រោកយឺតៗ ប៉ុន្តែភ្នែកមិនទាន់ដកពីទីនោះនៅឡើយទេ អ្នកដូចជាពិចារណាថាសម្តីដែលអ្នកស្រីកុលាបនិយាយថាយប់នោះភីណាខឹងបើកឡានចេញពីផ្ទះទាំងភ្លៀងទាំងយប់នោះ គឺដូចមិនសមហេតុផលសោះ តាមធម្មតាភីណាមានមនោសញ្ចេតនាល្អនឹងអ្នកស្រីបងថ្លៃណាស់ហេតុនេះនាងប្រាកដជាមិនធ្វើដូច្នោះទេ ប៉ុន្តែត្រិះរិះពីសម្តីដែលនាងក្រមុំភីណានិយាយប្រាប់អ្នកកំលោះម្តង នាងថាយប់នោះពេលឃើញបងថ្លៃខ្លួនស្លាប់ នាងរកទូរសព្ទ ទូរសព្ទក៏ប្រើមិនកើតទៀត ម្ល៉ោះហើយទើបនាងសុខចិត្តបើកឡានទាំងភ្លៀងចេញពីផ្ទះទៅរកអ្នកកំលោះ។

កំពុងលង់អារម្មណ៍ទៅក្នុងការត្រិះរិះ ត្រចៀកដូចមានស្តាប់ឮសូរសំឡេងអ្វីម្យ៉ាងយ៉ាងកម្សត់លាន់មកពីជាន់ខាងលើ។ វិទូងើបមុខសម្លឹងទៅរកប្រភពនៃសព្ទសូរសំឡេងយ៉ាងរហ័ស។ កណ្តាលបរិយាកាសស្ងាត់សូន្យសំឡេងតម្អូញយ៉ាងខ្សោយមួយកំពុងឮមកពីជាន់ខាងលើពិតប្រាកដណាស់។

អ្នកណាទៅហ្នំ? ហើយមកធ្វើអ្វីនៅខាងលើនោះ? បើពេលនេះសមាជិកក្នុងផ្ទះទៅក្រៅអស់ទៅហើយនោះ?

សំឡេងចម្លែកដែលមានលក្ខណៈកម្សត់ដូចសំឡេងតម្អូញរបស់អ្នកណាម្នាក់ កាន់តែជ្រៀតមកប៉ះសោតាច្បាស់ឡើងៗ ហាក់ដូចជាមានចេតនាធ្វើយ៉ាងណាឲ្យអ្នកកំលោះយើងអត់ទ្រាំទប់ចិត្តងឿងឆ្ងល់លែងកើតតទៅទៀត ទើបសម្រេចចិត្តថា ទោះបីជាយ៉ាងណាក៏ត្រូវឡើងទៅមើលដែរ ។អ្នកងាកឆ្វេងស្តាំសម្លឹងរកពូសួស ប៉ុន្តែបែរជាមិនឃើញគាត់សោះ មិនដឹងជាគាត់ទៅណាហើយទេ។

នាយប៉ូលិស ងាកទៅរកជណ្តើរសាជាថ្មី រួចឈានឡើងយឺតៗ តម្រង់ទៅជាន់ខាងលើក្នុងពេលដែលសូរសព្ទចម្លែកនៅតែម្តងឮម្តងឈប់។ ជើងឈានផុតពីជណ្តើរមួយកាំហើយមួយកាំទៀត សំឡេងកាន់តែឮច្បាស់ជាងមុន ហើយដែលវិទូអាចស្តាប់យល់ថា នោះគឺជាសូរសព្ទសោយសោករបស់នារីម្នាក់ស្រាលហើយខ្សោយ។

អារម្មណ៍មួយផុសផ្លោឡើងក្នុងចិត្តអ្នក ឬមួយថាភីណានាងត្រឡប់មកផ្ទះវិញ! ដោយឡើងទៅអង្គុយសោយសោកស្ងាត់ៗបែបនេះ?

គិតឃើញដូច្នេះហើយទើបអ្នកកំលោះសម្រេចចិត្តស្រែកហៅនាងពីជណ្តើរទៅ៖

-ភីណា? ភីណា? អូនមកផ្ទះវិញហើយអ្ហេស៎?

សូរសំឡេងសោយសោករលត់បាត់មួយរំពេច សភាពស្ងាត់ជ្រងំបានសណ្ឋិតក្នុងភូមិឋានដ៏ធំនេះសាជាថ្មីឡើងវិញ ការផ្លាស់ប្តូរតែមួយរំពេចនេះ រឹងរឹតតែធ្វើឲ្យអារម្មណ៍អ្នកកំលោះមិនស្ងប់ពីការសង្ស័យសោះ អ្នកកំលោះបន្លឺសួរសាជាថ្មីឡើងវិញនូវឃ្លាសំណួរដដែល៖

-ភីណា? យ៉ាងម៉េចហើយ? បងណ៎ា ចុះមកបងនៅខាងក្រោម!

ស្ងាត់ច្រៀប សំឡេងតបតែបន្តិចក៏គ្មានផង កណ្តាលសភាពស្ងាត់សូន្យសុងបែបនេះញ៉ាំងឲ្យអារម្មណ៍វិទូរឹតតែផ្អៀងទៅលើភាពជ្រួលច្រាល ណាមួយអ្នកដឹងថាខ្លួនបានឮសំឡេងគេយំច្បាស់ណាស់ ម៉េចក៏ពេលស្រែកសួរទៅ សូរសំឡេងនោះរលត់ហើយមិនឮមានអ្នកណាតបមកវិញសោះយ៉ាងនេះ?

លែងរវល់គិតច្រើន វិទូស្ទុះឡើងទៅយ៉ាងរហ័សទាំងក្នុងចិត្តបារម្ភខ្លាចក្រែងភីណាជួបប្រទះនូវរឿងអកុសលអ្វី? ប៉ុន្តែ ឡើងមកដល់ជាន់ខាងលើកាលណា សូម្បីតែស្រមោលមានជីវិតមួយក៏មិនឃើញមានផង។

វិទូងាកសម្លឹងបន្ទប់ទាំងអស់ដែលនៅព័ទ្ធជុំវិញមាត់ជណ្ដើរ បន្ទប់ណាមួយក៏បិទទ្វារជិតឈឹងដែរ រីឯបន្ទប់នាងក្រមុំម្ចាស់ស្នេហ៍ ដែលនៅឯចុងខាងឆ្វេងដៃនោះ មិនត្រឹមតែបិទទ្វារប៉ុណ្ណោះទេ ថែមទាំងបិទភ្លើងងងឹតស្លុបទៀតផង ដូច្នេះចិត្តមួយដែលគិតថាភីណាត្រឡប់មកវិញនោះប្រាកដជាខុសស្រឡះហើយ។ រួចចុះសំឡេងយំអម្បាញ់មិញ? វិទូលើដៃជ្រោងសក់ដោយតប់ប្រមល់

អ្នកគិតថា តាមមើលមកពីខ្លួនហត់នឿយពេកថែមទាំងអារម្មណ៍តឹងតែងទៀតទើបបានស្រមៃផ្ដេសផ្ដាសថាភីណាត្រឡប់មកវិញយ៉ាងនេះ។

អ្នកកំលោះបែរខ្លួនដើរចុះទៅខាងក្រោមវិញយឺតៗ ប៉ុន្តែទើបតែដើរចុះទៅបានបីជំហានប៉ុណ្ណោះ សូរសព្ទខ្សឹកខ្សួលសោយសោកខ្សោយៗមួយហើរពីទីណាមិនដឹងទេ ប៉ុន្តែវាបានកន្ត្រាក់ចិត្តវិទូឲ្យញាប់ញ័រពិតណាស់។

អ្នកកំលោះទុចដំណើរមួយរំពេច ដោយងាកសម្លឹងមកជាន់ខាងលើវិញយ៉ាងរហ័ស ម្ដងណេះលែងច្រឡំហើយ ពិតជាមានសំឡេងស្រីយំពិតណាស់ ណាមួយវិទូផ្ទៀងត្រចៀកស្ដាប់ទៅដូចជាដឹងថា សូរសព្ទសោយសោកនេះទំនងជាកំពុងលាន់ចេញពីក្នុងបន្ទប់មួយដែលនៅឯស្ដាំដៃទៀតផង។

អ្នកផ្ដោតភ្នែកសម្លឹងទៅកាន់ទីនោះ អ្នកស្គាល់ថានោះគឺជាបន្ទប់វត្ថុបុរាណ ដែលលោកកុសលអនាគតបងថ្លៃធ្លាប់បាននាំអ្នកឲ្យឡើងមកពិនិត្យមើលវត្ថុបុរាណច្រើនប្រភេទ ដែលគាត់តែងតែប្រមូលទិញយកមកតាំងជាសម្បត្តិគ្រួសារនៅទីនេះ រីឯសំឡេងយំយ៉ាងខ្សោយនោះ ហាក់ដូចជាកំពុងលាន់យ៉ាងកម្សត់ចេញមកពីទីនោះមែន។

កាន់តែស្ដាប់រឹតតែដឹងថា នុះមិនមែនជាសំឡេងយំរបស់ភីណាទេ ប៉ុន្តែ តើជាសំឡេងរបស់អ្នកណាទៅវិញ?

វិទូសម្លឹងទៅកាន់ទីនោះជាប់គ្មានព្រិច ឯជើងក៏កំពុងឈរយឺតៗតម្រង់ទៅកាន់បន្ទប់នោះដែរ ទ្វារបន្ទប់វត្ថុបុរាណបិទជិតឈឹងនៅពីមុខខ្លួន រីឯសំឡេងយំយ៉ាងកម្សត់នោះក៏កំពុងបន្តហើរមកប៉ះសោតាមិនមានឈប់សោះ វិទូលាន់មាត់ពោលសួរតិចៗ៖

-អ្នកណាយំហ្នឹង?

ម្តងនេះដូចលើកមុនអញ្ចឹងដែរ ទើបតែហាមាត់និយាយស្ទើរតែមិនទាន់បានបញ្ចប់ឃ្លាប្រយោគត្រឹមត្រូវផង សូរសំឡេងសោយសោកស្រាប់តែប្រែទៅជាបាត់ឈឹង ស្ងាត់ច្រៀបលែងឮសូរអ្វីទាំងអស់។

វិទូមិនអាចទប់ចិត្តទៅទៀតបានឡើយ អ្នកលូកដៃមួលសោរុញទ្វារបន្ទប់បើកយ៉ាងរហ័ស អ្នកបើកភ្នែកគ្រលួងសម្លឹងទ្វារបន្ទប់ដែលកំពុងរបើកទៅខាងក្នុងសន្សឹមៗ ផ្ទៃបន្ទប់ខាងក្នុងងងឹតស្លុបស្ទើរចាក់ភ្នែកមិនយល់ អ្នកកំលោះលូកដៃរាវចុចកុងតាក់ភ្លើង ភ្លើងបំភ្លឺចិញ្ចាចឡើង។ វិទូដៀងភ្នែកសម្លឹងទៅផ្ទៃបន្ទប់ដែលធំទូលាយ ប៉ុន្តែស្ងាត់ច្រៀប ស្រមោលមនុស្សម្នាក់ក៏គ្មានផង សម្លឹងឆ្ពោះទៅរានហាលខាងមុខបន្ទប់ក៏មិនមានស្រមោលមនុស្សម្នាក់សោះ វិទូចងចិញ្ចើមក៏ព្រោះតែក្តីងឿងឆ្ងល់កំពុងតែរុកកួនក្នុងចិត្តអ្នកដែរ អ្នកកំលោះដើរយឺតៗបើកកញ្ចក់ដើរចេញទៅកាន់រានហាលខាងមុខបន្ទប់ ដែលសំបូរទៅដោយខ្យល់បក់យ៉ាងត្រជាក់ស្រៀវស្រាញ។

នៅជ្រុងខាងឆ្វេងមានផើងថ្មមួយយ៉ាងធំ ដែលនៅខាងលើនោះ មានដើមផ្កាកុលាបច្រើនដើមសំបូរទៅដោយផ្កាពណ៌សរីករហង់ សឹងគ្រប់មែក វិទូសម្លឹងទៅដើមផ្កាដែលកំពុងយោលយោកទៅមកតាមកម្លាំងខ្យល់បក់ ខណៈនោះចុងភ្នែកប៉ះទៅនឹងពន្លឺអ្វីម្យ៉ាងជះមកពីទិសខាងត្បូង ហើយក៏ជាទិសដែលមានខ្យល់ត្រជាក់បក់មកយ៉ាងខ្លាំងនោះដែរ វិទូងាកសម្លឹងទៅកាន់ប្រភពនៃពន្លឺយ៉ាងរហ័ស។

ក្រសែភ្នែកវាត់ទៅដល់ទីដែលជាប្រភពនៃពន្លឺដែលជះមកនោះភ្លាម វិទូស្រងាកចិត្តត្បិតអីនោះគឺជាពន្លឺដែលជះចេញមកពីទូរទស្សន៍មួយសោះ គំនិតមួយលេចឡើងភ្លែតក្នុងចិត្តអ្នកកំលោះតាមមើលសូរសំឡេងយំកម្សត់ដែលខ្លួនបានឮអម្បាញ់មិញលាន់ចេញពីក្នុងទូរទស្សន៍ដែលកំពុងបើកចោលឯផ្ទះអ្នកជិតខាងនោះហើយ វិទូឈរច្រត់ចង្កេះសើចខឹកតែម្នាក់ឯង គេងើយមុខស្រូបយកអាកាសធាតុដ៏ត្រជាក់ល្ហឹម បន្ធូរអស់នូវអារម្មណ៍តឹងតែងទាំងប៉ុន្មាន តាមចរិតទាន់សម័យ និងសុទិដ្ឋិនិយមរបស់គេ។

ប៉ុន្តែមិនទាន់បន្ធូរ អារម្មណ៍បានប៉ុន្មានផង ស្នូរទូរសព្ទរោទ៍បានបណ្តាលឲ្យនាយប៉ូលិសភ្ញាក់រន្ធើនដោយពិភាល់។ លេខស្រីសម្លាញ់ចិត្តបង្ហាញលើអេក្រង់ឲ្យអ្នកប្រញាប់ចុចទទួលប៉ុន្តែសំឡេងទទួលបែរជាអ្នកផ្សេង៖

-វិទូ! ភីណាបង្ករឿងទៀតហើយ!

-បងសល? (វិទូភ្លាត់មាត់ទាំងក្តុកក្នុងចិត្ត)

អ្នកមិនទាន់សួរយ៉ាងណាផង សំឡេងលោកកុសលបន្លឺបន្តះ

-មកបឹងកេងកងមកទូ!

-បាទ! (វិទូឆ្លើយរអាក់រអួលព្រោះមិងមាំងមិនដឹងហេតុការណ៍)

គេស្ទុះចុះរឹងរត់សំដៅជំនិះដែលចតចោលហើយមិនបានទាំងឆ្លើយតបនឹងស្នាមញញឹមរបស់ពូសួសក៏ទៅ។ នៅតាមផ្លូវពាក្យថាភីណាបង្ករឿងកំពុងតែធ្វើឲ្យអ្នកកំលោះសង្ស័យទៅរកហេតុការណ៍អាក្រក់ៗ។ នាយប៉ូលិសនិយាយប្រាប់ខ្លួនឯងតិចៗថា "ភីណា!អូនអត់អីទេ!គឺអត់អីទាំងអស់!"

អ្នកកំលោះបោះបង់ចោលការគិតពីខ្លួនឯងព្រោះនឹកឃើញដល់តំណក់ទឹកភ្នែកស្រីស្អាតដែលទើបតែបែកគ្នាប៉ុន្មានម៉ោងមុននេះ។ ឥឡូវនេះតើនាងបង្ករឿងអ្វី? ហេតុអ្វី? នាងមានរឿងអ្វីបានជាគ្រប់គ្រងខ្លួនឯងមិនបានដល់ម្លឹង?

ជំនិះបញ្ជូនបុរសដែលកំពុងជ្រួលច្រាលចិត្តឲ្យមកដល់ Apartment បឹងកេងកងតាមសន្ទុះចិត្តនាយ។

មកដល់មាត់ទ្វារបន្ទប់នាជាន់ទី១២របស់នាង នាយឈានចូលយឺតៗព្រោះឃើញទ្វារបើកចំហដោយមានមីងម៉ាប់ទឹកមុខស្លេកស្លាំងឈរត្រុនៗនៅទីនោះផង។ គាត់យំឡើងភ្នែកក្រហមធ្វើឲ្យវិទូបោះបង់ចោលការចង់សាកសួរដោយស្ទុះចូលទៅរកបន្ទប់គេងរបស់ភីណា។

-បងកុសល! ឯណាភីណា?

មិនទាន់មានការឆ្លើយតបពីបុរសជាបងដែលកំពុងឈរទ្រឹងនោះនៅឡើយទេ ប៉ុន្តែវិទូបានឃើញ ភីណាទឹកមុខខ្មៅរោលកំពុងស្ថិតនៅលើដៃពេទ្យនារីពីរនាក់គ្រាត្រកងតម្រង់មកទ្វារ។ ស្ថានភាពនាងគឺបិទភ្នែកសន្លប់មិនដឹងខ្លួនទៅហើយ។

-មានរឿងអី?

អ្នកកំលោះសួរដោយតក់ស្លុត។ ស្ងាត់ច្រៀបគ្មានឮសំឡេងតបមកវិញមួយម៉ាត់ណាសោះ វិទូជ្រួញចិញ្ចើម លើកដៃបម្រុងអង្រួនកាយស្រីតូច តែត្រូវពេទ្យស្រីរាំងជាមួយប្រយោគនឹងនះ

-នាងត្រូវទៅពេទ្យជាបន្ទាន់! សូមជៀសផ្លូវ!

វិទូងាកមករកលោកកុសលចង្អុលទៅកាន់ប្អូនស្រីគាត់។ នាយប៉ូលិសហើបមាត់ពោលសួរសំណួរអ្វីក៏មិនចេញព្រោះគាំងអណ្តាតស្ទេញទៅហើយ។ លោកកុសលគ្រវីក្បាលហួសចិត្តប្រៀបដូចជាគាត់បានជួបរឿងដែលមិនសមថានិយាយកើត។ ទាល់តែពេទ្យគ្រាភីណាចេញផុតទើបគាត់និយាយដោយមិនសម្លឹងមុខវិទូ៖

-នៅសុខៗភីណាចង់លោតពីលើផ្ទះ!

វិទូស្រយុតអស់ដៃជើង។ អ្នកកំលោះងាកឆ្វាច់ទៅមើលស៊ីរាំងថ្នាំលើពូកដែលនៅដោយម្ជុលជាប់នៅឡើយ អ្នកកំលោះដឹងថានាងត្រូវគេចាប់ចាក់ថ្នាំសន្លប់ហើយទើបបញ្ឈប់ភាពកម្រោល។ សំឡេងមីងម៉ាប់យំលាន់មកធ្វើឲ្យវិទូភ្ញាក់អារម្មណ៍មកវិញហើយរត់ទៅតាមស្រីស្នេហ៍ដែលត្រូវបានគ្រាដល់មាត់ទ្វារ។ ពេលនោះប៉ៅអ៊ីបញ្ជូនអ្នកជំងឺបានមកដល់ គេបានដាក់នាងលើនោះរួចសែងចូលជណ្តើរយន្ត។ វិទូម្នីម្នារត់ចោលលោកកុសលដែលឈរភ្លឹកសំដៅទៅតាមនាងក្រមុំកម្សត់។

--------------------

ម៉ោង៩យប់នៅបរិវេណមន្ទីរពេទ្យ វិទូហុចទឹកក្រូចទៅឲ្យលោកកុសលដែលឈរស្ងៀមភ្លឹកភ្លាំងនៅរានហាលមុខបន្ទប់អ្នកជំងឺ។

-អ្នកបងទៅផ្ទះវិញហើយ។ ពេលទិញទឹកក្រូចខ្ញុំដើរមកជួបគ្នានឹងឡានគាត់ចេញ!

លោកកុសលនិយាយទាំងក្រៀមក្រំ៖

-កុលាបមិនចង់ទៅទេ! តែខ្លាចភីណាដឹងខ្លួនមកប៉ះទង្គិចអារម្មណ៍ទៀត!

កំលោះប៉ូលិសឆ្លៀតពេលសួរភ្លាម៖

-លោកបង! កន្លងមក ធ្លាប់ជ្រាបពីរឿងភីណាប្រើថ្នាំអស់ហ្នឹងទេ!

ទឹកមុខបុរសអភិជនប្រែទៅជាតឹងតែង។គាត់ងាកមកសម្លឹងអនាគតប្អូនថ្លៃយ៉ាងមុតហាក់ចង់ឲ្យគេជឿជាក់នូវអ្វីមួយដែលពិតជាពិបាកបកស្រាយជាខ្លាំងរហូតដល់និយាយមិនចេញ។

វិទូយល់ចិត្តគាត់ទើបបានងក់ក្បាលផ្ងក់ៗសម្រួលស្ថានការណ៍៖

-ខ្ញុំយល់ហើយ! អាចថាមួយរយៈក្រោយនេះភីណាស្មុគស្មាញចិត្តពេក!នេះជាកំហុសរបស់ខ្ញុំដែរដែលអត់សូវមានពេលយកចិត្តទុកដាក់ជាមួយនាង!

លោកកុសលនិយាយកាត់ដោយឈ្ងោកសម្លឹងតដ្ឋមិនហ៊ានសម្លឹងវិទូ៖

-បងនៅតែយល់ថា ប្អូនស្រីបងមិនដើរផ្លូវហ្នឹងទេ! បងមិនជឿដាច់ខាត!

នាយប៉ូលិសវ័យក្មេងដៀងភ្នែកសម្លឹងបងថ្លៃដោយមិនចេញស្តី ប៉ុន្តែតាមពិតគេក៏កំពុងចម្លែកចិត្ត។ទោះបីយ៉ាងណាគ្មានអ្នកណាម្នាក់ជឿទេថាភីណាសេពគ្រឿងញៀនទោះបីជារបាយការណ៍របស់មន្ទីរពេទ្យអះអាងថានាងមានជាតិញៀនក្នុងខ្លួនក្នុងកម្រិតខ្ពស់ជាហេតុធ្វើឲ្យរវើរវាយដល់ថ្នាក់ចង់សម្លាប់ខ្លួនក្តី។ ប៉ុន្តែបើនាងមិនសម ចុះការពិតចំពោះមុខនេះវាយ៉ាងណាវិញពិសេសអ្នកកំលោះទើបតែជួបនិយាយលួងលោមនាងថ្មីៗសោះ ហេតុអ្វីបានជានាងធ្វើរឿងនេះទៅរួច? ចុះអ្នកណាជាអ្នករកគ្រឿងញៀនឲ្យនាង? នាងជាកូនស្រីអ្នកមានកម្រចេញពីផ្ទះ មួយរយៈនេះឈឺដល់ថ្នាក់មហាវិទ្យាល័យក៏មិនទាន់ទៅរៀនវិញកើតផង?

ស្នូរទូរសព្ទលាន់មករន្ថើនធ្វើឲ្យនាយត្រូវឈប់ជំនិះហើយលើកមកស្តាប់។

-ទូ! របាយការណ៍ចេញមកហើយ!

វិទូភ្ញាក់ផ្អើលគេនិយាយបន្ថែម៖

-ល្អណាស់ភ័ណ! ខ្ញុំកំពុងចង់ដឹង! តើយ៉ាងម៉េចហើយ? របាយការណ៍រកឃើញអីខ្លះ?

សំឡេងពីចុងម្ខាងនិយាយតប៖

-យើងគួរជួបគ្នាបន្តិចទៅល្អជាង!

វិទូសម្រួលទឹកមុខតបទៅវិញ៖

-បាន! ចាំខ្ញុំនៅស្នងការ! ខ្ញុំទៅដល់ឥឡូវហើយ!

ភាគទី១៦

វគ្គទី៨

បន្ទប់វត្ថុបុរាណ

នៅក្រោមអំពូលពណ៌ពងមាន់ក្រហមព្រឹមៗ កំលោះវិទូឈ្ងោកអានឯកសារមួយសំណុំដោយទឹកមុខភ្ញាក់ផ្អើលស្របពេលសំឡេងមិត្តលាន់មកក្បែរត្រចៀកៈ

-របាយការណ៍នេះច្បាស់ណាស់គឺភីណាទើបតែប្រើវាទេ គឺគ្រឿងញៀនច្រើនប្រភេទលាយលំគ្នា!ភាគច្រើនជាប្រភេទសំយោគកែច្នៃពីជាតិគីមីដែលEffectedទៅលើខួរក្បាលនិងប្រព័ន្ធសរសៃប្រសាទ! សំយោគចុងក្រោយបង្ហាញថាក្នុងឈាមនាងនៅមានជាតិអេស្តាស៊ី អំហ្វេតាមីនហេរ៉ូអ៊ីនលាយឡំគ្នា ប៉ុន្តែជាតិញៀនអស់នេះបែរនៅលាយឡំជាមួយប្រូតេអ៊ីនយ៉ាងច្រើនគួរឲ្យប្លែកដែរ!បើគេផលិតគ្រឿងញៀនសំយោគគេចាំបាច់អីលាយជាមួយប្រូតេអ៊ីន! វាមានតែ...

វិទូងើបមុខសម្លឹងវេជ្ជបណ្ឌិតផ្នែកឱសថសាស្ត្រដែលនៅចំពោះមុខខ្លួន។ ក្រសែភ្នែកនាយហាក់ចង់តឿនថាឲ្យគេនិយាយឲ្យអស់ភ្លាមមកព្រោះខ្លួនកំពុងចង់ដឹងជាខ្លាំង។ បុរសជាមិត្តមិនបង្អង់ក៏និយាយបន្ថែមភ្លាមៈ

-ខ្ញុំយល់ថានាងដូចជាប្រើវាជាមួយម្ហូបដែលមានប្រូតេអ៊ីនខ្ពស់ ឬមួយថាមានអ្នកណាម្នាក់លួចដាក់ថ្នាំនេះទៅក្នុងអាហាររបស់នាងក៏ថាបាន!

វិទូរភ្នែកសញ្ជឹងគិត។ ភ្លាមនោះអ្នកកំលោះងើបមុខពោលសួរៈ

-អាចជាសាច់គោទេភ័ណ?

វេជ្ជបណ្ឌិតឱសថសាស្ត្រងក់ក្បាលៈ

-វាអាច! ប្រសិនបើចង់គឺយើងត្រូវយកកាកសំណល់ពីក្រពះនាងទៅវិភាគទៀតប៉ុន្តែពេលនេះហួស៦ម៉ោងទៅហើយ វាអត់បានការទេវិទូ!

វិទូក្តាប់មាត់ នាយនិយាយតបៈ

-ខ្ញុំមានមធ្យោបាយដឹងរឿងនេះ! អរគុណណាស់ភ័ណ!

-មិនបាច់គុណស្រ័យទេ! ប៉ុន្តែមានរឿងមួយទៀតខ្ញុំចង់បញ្ជាក់ប្រាប់ទូងឯងឲ្យច្បាស់ គ្រឿងញៀនប្រភេទអេស្តាស៊ីអាចធ្វើឲ្យមនុស្សសប្បាយរំភើបភ្លាមៗដោយមិនដឹងរឿង ប៉ុន្តែបើគេសំយោគវាជាមួយសារធាតុចិញ្ចឹមផ្សេងៗគឺអាចធ្វើឲ្យអារម្មណ៍មនុស្សផ្លាស់ប្តូរលឿនដូចផ្លេកបន្ទោរទៅជាស្រងេះស្រងោចក្រៀមស្រពោនបាន!

-អាចដល់សម្លាប់ខ្លួនឯងទេ? (វិទូពោលសួរដោយក្រសៃភ្នែកមុតថ្លា)

-អាច! អាស្រ័យទៅលើភាពរឹងមាំរបស់បុគ្គលនោះផ្ទាល់ទៀត! បើសិនមួយរយៈនេះគេមានអ្វីមួយប៉ះទង្គិចដល់អារម្មណ៍ខ្លាំង កម្រិតថ្នាំកាន់តែនាំឲ្យមានគ្រោះថ្នាក់ទ្វេគុណ!

វិទូចាកចេញពីស្នងការដ្ឋាននៅចំពេលព្រលប់។ អ្នកកំលោះតាមពិតចង់ជួបមីងម៉ាប់ដែលនៅជាមួយភីណាចុងក្រោយគេ មុនពេលនាងកើតរឿងនៅឯApartment បឹងកេងកង ប៉ុន្តែដោយសារតែ ទីនោះត្រូវចាក់សោជិតឈឹងទៅហើយអ្នកកំលោះក៏បកមកកាន់ផ្ទះធំដើម្បីរកគាត់សួរនាំហេតុការណ៍។

នៅផ្ទះធំក្រៅពីពូសួសចេញមកបើកទ្វារដូចសព្វមួយដង កំលោះប៉ូលិសមិនបានជួបអ្នកបម្រើស្រីណាម្នាក់ដូចចិត្តប៉ងនោះទេ។ អ្នកកំលោះចូលមកដល់បន្ទប់ធំ ក៏វាក់អ៊ើនឹងអ្នកស្រីវ័យក្មេងដែលមុននេះអ្នកកំលោះបានដើរបញ្ច្រាសនឹងរថយន្តរបស់គាត់ពេលចាកចេញពីមន្ទីរពេទ្យ។

-ប្អូនទូអត់បាននៅមន្ទីរពេទ្យជាមួយភីណាទេ?

ស្ត្រីនោះសួរមកកាន់បុរសអនាគតប្អូនថ្លៃដោយមិនចោលភាពក្រៀមក្រំលើផ្ទៃមុខបង្ហាញពីការយកចិត្តទុកដាក់របស់គាត់ចំពោះភីណាដែលនៅដេកស្តូកស្តឹងទទួលការថែទាំក្នុងមន្ទីរពេទ្យនៅឡើយ។ អ្នកកំលោះនិយាយតប៖

-ភីណាលែងអីហើយ! នាងគ្រាន់តែត្រូវការសម្រាកពីរបីថ្ងៃ! ខ្ញុំមកនេះចង់សុំជួបនិយាយជាមួយអ្នកផ្ទះអ្នកបងពីរបីម៉ាត់! គឺចង់សួររឿងហេតុនៅ Apartmentបឹងកេងកង!

អ្នកស្រីវ័យក្មេងបើកភ្នែកមូលក្រឡង់។ គាត់និយាយមួយៗហាក់សោកស្តាយ៖

-អ្នកអួនទៅមើលថែអ្នកនាងនៅពេទ្យហើយ! ឯអ្នកម៉ាប់សុំច្បាប់ថាទៅផ្ទះព្រោះមិនស្រួលខ្លួន! គាត់ទើបតែជិះឡានឈ្នួលចេញមុននេះកន្លះម៉ោងហ្នឹង!

គឺអ្នកម៉ាប់នោះហើយដែលជាសាក្សីសំខាន់នៃសំណុំរឿងនេះ មានរឿងអ្វីបានជាគាត់ស្រាប់តែចាកចេញភ្លាមៗអញ្ចឹង? ហេតុអ្វីក៏ពេលនេះវិទូស្រាប់តែចាប់អារម្មណ៍ថាអ្វីៗដូចជានៅក្រោយដានជើងរបស់អ្នកណាម្នាក់ដែលបានឈានទៅមុនអ្នកកំលោះមួយជំហានវែងទៅហើយ។ នាយងើបមុខទៅរកទឹកមុខស្លូតបូតរបស់ស្ត្រីដែលស្អាតផ្ដាច់គេនៃគេហដ្ឋាននេះ អ្នកកំលោះសំណូមពរទៅកាន់គាត់៖

-អ្នកបង! ខ្ញុំសុំលេខទំនាក់ទំនងមីងម៉ាប់ឬក៏អាសយដ្ឋានផ្ទះគាត់នៅឯស្រុកក៏បាន!

ស្ត្រីអភិជនវ័យក្មេងប្រញាប់ប្រញាល់ពោលតបភ្លាមដោយសារឃើញទឹកមុខនាយប៉ូលិសមធ្យ័តពេក៖

-អញ្ជើញអង្គុយសិនទៅលោកក្មួយ! ខ្ញុំឡើងទៅរកមើលសិន!

វិទូញញឹមគួរសមឆ្លើយតបទៅនឹងគាត់៖

-បាទ! អរគុណអ្នកបងណាស់!

អ្នកស្រីកុលាបនាំកាយទន់ភ្លន់រវៀសរវៃឡើងជណ្ដើរធ្វើឲ្យវិទូដែលតាមសម្លឹងពីក្រោយនឹកភ្នកដល់សម្ដីរៀបរាប់របស់កញ្ញាជាគូដណ្ដឹងដែលទាក់ទងនឹងរាត្រីភ្លៀងធំ។ គេលូកដៃលើកយកតេឡេបញ្ជាទូរទស្សន៍ចុចបើកបន្លប់ចិត្តរាយប៉ាយដោយតាំងអារម្មណ៍មកវិញថាមិនយកសម្ដីនាងគិតទៀតឡើយព្រោះថានាងអាចនឹងនិយាយរឿងទាំងនោះដោយភាពរវើរវាយរបស់នាងក្រោមឥទ្ធិពលសារធាតុញៀន។

ម្នាក់ឯងកណ្ដាលបន្ទប់ធំល្វឹងស្ងាត់ជ្រងំ អ្នកទទួលអារម្មណ៍ថាធុញទ្រាន់ណាស់។ ផ្ទះធំដល់ម្លឹងតែស្ងាត់ដល់ម្លឹង  ប្រសិនបើនាងក្រមុំគូស្នេហ៍ត្រឡប់មកទ្រាំទ្រជាមួយបរិយាកាសនៃគេហដ្ឋានបែបនេះក៏ប្រាកដជានាងពិបាកឆ្លងកាត់ដែរ។ មួយដង្ហើមណាក៏គិតពីនាង ហើយយល់ថាអាណិតនាងដែលត្រូវរស់ក្នុងស្ថានភាពនេះ...

អ្នកកំលោះលូកដៃលើកយកតេឡេបញ្ជាទូរទស្សន៍មកចុចប្ដូរប៉ុស្តិ៍ ខ្សែភាពយន្តបរទេសកំពុងបង្ហាញខ្លួននៅគ្រប់ប៉ុស្តិ៍ទូរទស្សន៍ទាំងអស់ វិទូយល់ថារឹតតែតប់ប្រមល់ក្នុងចិត្តណាស់ទៅទៀត អ្នក កំលោះលូកដៃចុចបិទរួចទម្លាក់តេឡេដៃបញ្ជាចោលមកលើសាឡុងវិញដោយផ្អែកខ្នងទៅនឹងបង្អែកសាឡុងធ្មេចភ្នែករំងាប់ភាពហត់នឿយទាំងប៉ុន្មាន ដែលបានផ្ទុកក្នុងក្បាល

ពេញមួយថ្ងៃមកហើយ ប៉ុន្តែទើបតែធ្មេចបានប្រមាណមួយដង្ហើមប៉ុណ្ណោះ ត្រចៀកស្រាប់តែឮសូរស្នូរជើងរត់ខ្លាំងធ្ងន់ៗហាក់ដូចជាអ្នកដែលរត់នោះកំពុងស្ថិតនៅចំពោះមុខស្ថានភាពតក់ក្រហល់អ្វីមួយ។

អ្នកកំលោះបើកភ្នែកវិញខ្វាក ព្រមពេលក្រសែភ្នែកដំបូងបង្អស់វាត់ប៉ះទៅនឹងរូបរាងស្ត្រីជាអនាគតបងថ្លៃដែលមុននេះឡើងទៅជាន់ខាងលើអម្បាញ់មិញ ឥឡូវនេះគាត់កំពុងរត់ចុះមកក្រោមតាមជណ្ដើរដោយអាការស្លន់ស្លោទឹកមុខស្លេកស្លាំង។ អាការរបស់គាត់ដូចបានជួបប្រទះនូវហេតុការណ៍គួរឲ្យតក់ស្លុតណាមួយធ្វើឲ្យអ្នកកំលោះស្ទុះក្រោកឈរពោលសួរយ៉ាងរហ័ស៖

-អ្នកបង? មានរឿងអី?

ស្ត្រីរូបនេះរត់ចុះមកដល់ក្រោមកាលណា គាត់ស្ទុះមកជិតអ្នកកំលោះ ពោលដោយទឹកមុខភិតភ័យ៖

-...មាន...មានខ្មោច!

វិទូបើកភ្នែកគ្រលួងកាលបើត្រចៀកបានស្ដាប់ឮសម្ដីឆ្លើយតបដំបូងបង្អស់នេះ អ្នកត្រិះរិះដោយក្ដីតប់ប្រមល់៖

-ខ្មោចទៀតហើយ?

ភ្លាមនោះអ្នកពោលសួរទៅកាន់គាត់៖

-ខ្មោចនៅឯណា?

អ្នកស្រីកុលាប លើកដៃចង្អុលទៅជាន់ខាងលើដោយទឹកមុខស្វាយល្អក់ គាត់មិនទាន់ហើបមាត់និយាយបន្ថែមថាយ៉ាងណានៅឡើយ អ្នកកំលោះស្ទុះរឹងឡើងតម្រង់ទៅជាន់ខាងលើភ្លាម។

មកដល់មាត់ជណ្ដើរនៃជាន់ខាងលើដែលមានបើកភ្លើងភ្លឺចិញ្ចាច អ្នកដៀងភ្នែកសម្លឹងបរិយាកាសស្ងាត់ឈឹងដែលនៅជុំវិញទីនេះ ភ្លាមនោះអ្នកឮសំឡេងអ្នកស្រីកុលាបពោលស្រាលៗមកពីក្រោយខ្នង៖

-ប្អូនទូ! គឺនៅ...នៅ...បន្ទប់ដាក់វត្ថុបុរាណ!

អ្នកកំលោះងាកភ្លែតទៅរកបន្ទប់វត្ថុបុរាណដែលនៅខាងស្ដាំដៃ តាមដែលឮអ្នកស្រីរូបនេះពោលប្រាប់។ ទ្វារបន្ទប់នៅតែបិទជិតដូចកាលពីយប់ម្សិលដែលអ្នកបានឮសំឡេងគេយំសោកល្ងើយៗនោះដែរ ប៉ុន្តែម្ដងនេះ ត្រចៀកបែរជាស្ដាប់ឮដូចជាសូរអ្នកណាកំពុងកាប់អ្វីមួយទៅវិញ វិទូឈានយឺតៗចូលទៅកាន់ទីនោះដោយមានស្ត្រីរូបស្អាតតាមមកពីក្រោយផង។

អ្នកកំលោះនៅចាំបានថា កាលយប់មុនដែលខ្លួនបានស្ដាប់ឮសំឡេងមនុស្សស្រីយំលាន់ចេញមកពីក្នុងបន្ទប់នេះ ពេលដែលស្រែកសួរទៅ ស្រាប់តែសំឡេងយំនោះបែរជារលត់បាត់ស្ងាត់ឈឹងមួយរំពេច ម៉្លោះហើយលើកនេះអ្នកយល់ថា ត្រូវដើរលបចូលទៅមើលដោយស្ងាត់ៗវិញម្ដងទើបល្អ។

អ្នកកំលោះបោះជំហានចូលកាន់ជិតទៅៗ ក្នុងពេលដែលត្រចៀកបានឮសូរសំឡេងគេកាប់របស់អ្វីនោះក៏កាន់តែច្បាស់ឡើងៗដែរ។

នាយឈានមកដល់ពីមុខទ្វារ ប៉ុន្តែនៅមិនទាន់លូកដៃមួលសោនៅឡើយ អ្នកងាកមករកស្ត្រីដែលកំពុងតែឈរពីក្រោយខ្នងទាំងពោលប្រាប់៖

-ទោះឃើញអីក៏ដោយ អ្នកបងកុំស្រែកឲ្យសោះ!

អ្នកស្រីកុលាបងក់ក្បាលផ្ងក់ៗដោយទឹកមុខស្លេកស្លាំង វិទូងាកមកវិញសម្លឹងទ្វារបន្ទប់បន្តិចរួចទើបសម្រេចចិត្តលូកដៃមួលសោទ្វារបន្ទប់រុញចូលទៅខាងក្នុង ម្ដងនេះក៏ដូចកាលពីយប់មុនដែរ ទ្វាររបើកទៅក្នុងបង្ហាញផ្ទៃបន្ទប់ដែលធំទូលាយ ហើយងងឹតស្លុប ប៉ុន្តែម្ដងណេះវិទូមិនលូកដៃបើកភ្លើងទៀតទេ។ អ្នករាវដើរចូលលបៗទៅក្នុងបន្ទប់ កណ្ដាលភាពងងឹតសូន្យសុងប៉ុន្តែត្រចៀកបានស្ដាប់ឮស្នូរគេកាប់អ្វីមួយឯរានហាលខាងមុខបន្ទប់ពិតណាស់។

វិទូដៀងភ្នែកសម្លឹងទៅតាមបង្អួចកញ្ចក់ដែលបិទមិនទាន់ជិតនៅឡើយ អ្នកដឹងថាក៏ព្រោះតែយ៉ាងនេះហើយ ទើបសំឡេងនោះឮពីរានហាលចូលមកក្នុងបន្ទប់បានតាមចន្លោះបង្អួចដែលបិទមិនទាន់ជិតនោះឯង អ្នកដើរយឺតៗទៅជិតបង្អួច ជាមួយគ្នានោះដែរ សំឡេងចម្លែករឹតតែលាន់ឮយ៉ាងច្បាស់មកប៉ះសោតាអ្នកកំលោះយើងខ្លាំងជាងមុនទៅទៀត អ្នកកំលោះអើត

សម្លឹងទៅរានហាលខាងក្រៅក៏ស្រាប់តែត្រូវធ្លាក់ថ្លើមក្តុក ត្បិតអីអ្នកកំលោះឃើញបុរសប្លែកមុខពីរនាក់កំពុងកាន់ពូថៅនៅនឹងដៃ នាំគ្នាកាប់បំបែកចូផ្កាកុលាបដ៏ធំដែលសន្ធឹងពីមុខរានហាលប្រកបដោយផ្ការាប់សិបដើមស្អេកស្កះ។

អ្នកស្ទុះរឹងមកបើកទ្វារកញ្ចក់ដោយស្ទុះចេញទៅរានហាលយ៉ាងរហ័សជាមួយនឹងប្រយោគគំហកសួរលាន់ខ្ទររាត្រីស្ងាត់៖

-ពួកឯងនាំគ្នាធ្វើអី?

បុរសពីរនាក់ដែលកំពុងកាប់គាស់ផើងផ្កាដោយអាការប្រញាប់ប្រញាល់នោះ បញ្ឈប់ដៃជាបន្ទាន់ ប៉ុន្តែគេទាំងពីរកំពុងក្តាប់ដងពូថៅជាប់យ៉ាងណែនដោយបើកភ្នែកក្រឡេត ងាកសម្លឹងមកកាន់វិទូវិញ។ អ្នកកំលោះដកកាំភ្លើងពីចង្កេះយ៉ាងរហ័សភ្ជង់តម្រង់ទៅកាន់មនុស្សចម្លែកទាំងពីរ ដែលគ្រាន់តែមើលក៏អ្នកដឹងថា ពួកគេគឺលួចចូលមកក្នុងបំណងមិនល្អពិតណាស់ អ្នកកំលោះពោលទៅកាន់ពួកគេដោយទឹកមុខម៉ឺងម៉ាត់៖

-ទម្លាក់ពូថៅចុះ បើមិនអញ្ចឹងទេ យើងបាញ់ភ្លាម!

ពូថៅលើដៃគេទាំងពីរត្រូវទម្លាក់ឆឹងទៅលើកម្រាលឥដ្ឋ ល្មមពេលដែលអ្នកស្រីកុលាបនៅខាងក្នុងចុចភ្លើងភ្លឺចិញ្ចាច។ វិទូផ្តោតភ្នែកសម្លឹងទៅកាន់ជនចម្លែកទាំងពីរដោយពិនិត្យពិច័យ។ ជាមួយនឹងផ្ទៃមុខស្លេកស្លាំងរបស់ពួកគេ អ្នកកំលោះគិតមិនយល់ថាគេមិនមែនជាចោរទេព្រោះឡើងមកនេះមិនចូលក្នុងបន្ទប់បែរជាសំងំនាំគ្នាកាប់ផើងផ្កា ចុះម៉េចក៏កណ្តាលយប់ស្ងាត់ហ៊ានលួចឡើងមកគេហដ្ឋានអ្នកដទៃប្រព្រឹត្តអំពើកាប់គាស់ស្រេចនឹងចិត្តបែបនេះទៅវិញ?

កំពុងពិចារណាពីរឿងហេតុចំពោះមុខនេះ ក៏ស្រាប់តែភ្លាមនោះ ជនម្នាក់ដែលឈរកៀកនឹងរបងជាងគេស្ទុះរឹងលោតចុះទៅខាងក្រោមយ៉ាងរហ័សរាងកាយនោះធ្លាក់ប្រុងទៅក្នុងអាងហែលទឹកដែលស្ថិតនៅខាងក្រោយគេហដ្ឋាន រកតែវិទូបញ្ចេញប្រតិកម្មរាំងយ៉ាងណាក៏មិនទាន់ដែរ ជនម្នាក់ទៀតដែលនៅសល់នោះ ឆ្លៀតឱកាសប្រចុចញ៉ុចដែលអ្នកកំលោះវិទូកំពុងភាន់ភាំង យារជើងតម្រង់មកក្នុងបំណងទម្លាក់អាវុធពីដៃនាយនឹងអាលរំដោះខ្លួនទៅតាមគូកនដែលនៅខាងក្រោម ប៉ុន្តែរហ័សដូចផ្លេកបន្ទោរ វិទូមិនមែនត្រឹមតែអាចថយរក្សាអាវុធជាប់ម៉ឺងក្នុងប្រអប់ដៃតែប៉ុណ្ណោះទេ គេថែមទាំងក្រឡាស់ខ្លួនសងមួយស្មៀតវិញ បណ្តាលឲ្យជននោះ

ភ្លាត់ចំណាប់ដួលប្រុសទៅលើកម្រាលឥដ្ឋ រីឯកាំភ្លើងលើដៃវិទូនៅភ្ជង់ចំកណ្តាលថ្ងាសជាប់ដដែល។

វិទូបង្ក្រាបបានអ្នកនៅខាងលើហើយក៏ពិតមែន ប៉ុន្តែអ្នកកំលោះងាកទៅរកអ្នកដែលធ្លាក់ទៅខាងក្រោមនោះទាំងមិនអស់ចិត្តត្បិតអី ក្រោមពន្លឺភ្លឺស្រទន់នៃរង់ចន្ទ្រាដែលបំភ្លឺមក អ្នកឃើញជននោះក្រោកចេញពីអាងហែលទឹកតម្រង់ទៅកាន់ទ្វារខាងក្រោយយ៉ាងរហ័សរហួនបំផុត អ្នកកំលោះនឹកមួហ្មងក្នុងចិត្តណាស់ មិនសមណាមកទាន់នឹងភ្នែកនៅតែឲ្យរត់រួចបានម្នាក់យ៉ាងនេះ ប៉ុន្តែក្នុងខណៈនោះដៃររថយន្តរបស់ក្រុមប៉ូលិសបានបោលមកឈប់រាំងពីមាត់ទ្វារយ៉ាងរហ័ស ដោយមានក្រុមប៉ូលិសហក់ព្រូៗចុះមករាយគ្នាចោមរោមចាប់ជននោះ បណ្តាលឲ្យជននោះស្ថិតនៅពីមុខនៃការទាល់ច្រកវិញមួយរំពេច។

ទោះជាបន្ទាន់យ៉ាងនេះ វិទូនឹកមិនដល់ថា តើអ្នកណាជាអ្នកប្តឹងប៉ូលិសទាន់ពេលវេលានោះក៏ពិតមែន ប៉ុន្តែអ្នកនៅតែគិតរួចជាស្រេចហើយថា ជននោះលែងរត់រួចទៀតហើយ។

នៅឯខាងលើឯណោះវិញ បម្រើប្រុសម្នាក់ទៀតដែលអម្បាញ់មិញស្ថិតនៅខាងក្រោមនៅឡើយក៏បានសម្រុកចូលមកក្នុងបន្ទប់ជាមួយវាចាសួរៈ

-មានរឿងអី? មានរឿងអី?

វិទូលាន់មាត់ប្រាប់ទៅពូសួសៈ

-ពូនាំវានេះចុះទៅក្រោមប្រគល់ឲ្យប៉ូលិសចុះ !

ជនល្មើសដែលកំពុងភ្លាត់ចំណាប់ដួលនៅដីក្រោកមិនទាន់រួចផងនោះត្រូវពូសួសចូលមកអូសកនាំចុះទៅតាមពីក្រោយ វិទូដែលកំពុងដើរយឺតៗចុះទៅខាងក្រោម។

សំឡេងអ្នកស្រីកុលាបរអ៊ូរងំពីក្រោយខ្នងវិទូៈ

-ពូអើយ! ខ្ញុំឯណោះភ័យអស់ព្រលឹងព្រលះនឹកស្មានថាខ្មោចលង តាមពិតគឺចោរសោះ! ចេះបានវិទូនៅកុំអីវីវរហើយ!

វិទូមកដល់ជាន់ខាងក្រោមក៏ប្រទះឃើញមិត្តរួមការងារដែលស្ថិតនៅទីស្នាក់ការជាមួយគ្នាចាប់បានជនល្មើសដែលព្យាយាមលោតគេចនោះដាក់ខ្នោះរុញឡើងទៅលើឡាន នៅឯម្ខាង

ពេលនោះអ្នកឃើញក្មេងជំទង់ដែលស្ថិតនៅផ្ទះជាប់ខាងរបងនេះ កំពុងឆ្ការដៃឆ្ការជើងនិយាយជាមួយក្រុមប៉ូលិសដែលសុទ្ធសឹងជាអ្នករួមការងាររបស់វិទូ។ អ្នកកំលោះដើរចូលទៅជិតឮក្មេងជំទង់សំណាងនោះពោលខ្លាំងៗ៖

-ដំបូងខ្ញុំចេញមកក្រៅទន្ទេញមេរៀន ក៏ស្រាប់តែឮសូរសំឡេងដូចមិនធម្មតា ក៏ឡើងលើរានហាលសម្លឹងមើលមកផ្ទះជាប់គ្នានេះ ខ្ញុំឃើញពីរនាក់នោះកំពុងកាន់ពូថៅម្នាក់មួយឈររេរាមុខបន្ទប់ ខ្ញុំភ័យណាស់ក៏រត់ទៅរកប៉ូលិសភ្លាមទៅ។

វិទូដើរចូលទៅជិតវាដោយទះស្មាវាពីក្រោយតិចៗដោយពោលទៅកាន់ក្មេងសំណាងទាំងញញឹម៖

-ប្អូនរកប៉ូលិសទាន់ពេលល្អណាស់ ចំជាអ្នកជិតខាងល្អមែន!

ក្មេងជំទង់ងាកមករកវិទូ វាញញឹមបង្ហាញអាការរីករាយ៖

-បងវិទូ! បងក៏នៅទីនេះដែរ? អញ្ចឹងប្រសើរណាស់។

អ្នកកំលោះវិទូញញឹមមិនតប ហើយងាកទៅរកក្រុមប៉ូលិសដែលកំពុងស្ទុះមកក្បែរ ម្នាក់ក្នុងចំណោមក្រុមប៉ូលិសពោលមកកាន់វិទូ៖

-បងវិទូក៏នៅទីនេះដែរ? អុះនែ៎វាទាំងពីរគិតយ៉ាងម៉េច?

វិទូតបដោយសម្លឹងទៅជនល្មើសទាំងពីរដែលកំពុងស្ថិតនៅលើឡាន៖

-បញ្ជូនទៅកន្លែងយើង ព្រឹកស្អែកសួរចម្លើយ!

ពួកប៉ូលិសធ្វើការរបស់ពួកគេដោយល្អិតល្អន់រួចទើបនាំយកជនល្មើសពីរនាក់នោះទៅកាន់ទីស្នាក់ការ។ ឯវិទូអ្នកងាកទៅប្រាប់អ្នកស្រីជាបងដែលនៅមិនទាន់បាត់ភ័យបារម្ភនៅឡើយ៖

-អ្នកបងឈប់បារម្ភទៅ លែងអីហើយ! លោកបងបានទទួលដំណឹងហើយ គាត់កំពុងនៅតាមផ្លូវត្រឡប់មកផ្ទះ!

យប់នោះវិទូបើកម៉ូតូត្រឡប់មកកាន់ប៉ុស្តិ៍បណ្ដើរ រិះគិតបណ្ដើរ។ អ្នកនៅចាំមិនភ្លេចនៅឡើយទេ នូវសម្ដីរបស់នាងក្រមុំគូស្នេហ៍ដែលប្រាប់ថា កាលពីរាត្រីដែលមានភ្លៀងធ្លាក់នោះ នាងនិងបងថ្លៃបានឡើងទៅកាន់ជាន់ខាងលើតាមដែលឮសំឡេងមនុស្សរត់នៅជាន់នោះ ណា

មួយនាងបាននិយាយថា យប់នោះខ្លួននិងបងថ្លៃបានចូលក្នុងបន្ទប់វត្ថុបុរាណ រួចហើយប្រទះឃើញបុរសប្លែកមុខពីរនាក់លើដៃពួកគេមានកាន់ពូថៅមួយម្នាក់ទៀតផង ឬមួយថាពីរនាក់ដែលភីណានិយាយនោះ និងពីរនាក់ដែលចាប់បានក្នុងថ្ងៃនេះ គឺជាមនុស្សដដែលទេ?

បើសិនជាអញ្ចឹងមែន សម្ដីដែលភីណានិយាយថានាងនិងបងថ្លៃបានភិតភ័យរត់ចុះមកខាងក្រោមរហូតដល់បងថ្លៃនាងគាត់ទាក់ជើងដួលតាមជណ្ដើរមកដល់ក្រោមរហូតដល់ដាច់ខ្យល់នៅនឹងកន្លែងនោះ ក្រែងជាពាក្យពិតទេដឹង?

រួចចុះពីរនាក់នោះវាឡើងមករានហាលកាប់បំផ្លាញផើងផ្កាកុលាបទាំងយប់ក្នុងបំណងអ្វី? ម៉េចក៏ការប្រព្រឹត្តនេះដូចជាចម្លែកម្ល៉េះ? បើថាជាចោរក៏ដូចជាមិនមែន បើចង់ដឹងច្បាស់មានតែរង់ចាំដល់ថ្ងៃស្អែកប៉ុណ្ណោះ។

វិទូជាមួយមិត្តរួមការងារបីនាក់ទៀតចូលសួរចម្លើយជនល្មើសទាំងពីរជាមួយគ្នាក្នុងពេលតែមួយ។ វិទូសម្លឹងទៅជនល្មើសទាំងពីរដែលកំពុងឈ្ងោកមុខជ្រប់ក្រោមក្រសែភ្នែកពិនិត្យពិច័យរបស់ក្រុមប៉ូលិស អ្នកកំលោះលាន់មាត់សួរមុនគេទាំងអស់៖

-កណ្ដាលយប់ស្ងាត់ ពីរនាក់ឯងលួចឡើងទៅលើផ្ទះគេដៃមានកាន់ទាំងពូថៅផង តើមានបំណងស្អី?

ជនល្មើសទាំងពីរនោះដៀងភ្នែកមើលមុខគ្នា ប៉ុន្តែនៅមិនទាន់ចេញស្ដីថាយ៉ាងណានៅឡើយទេ ភ្លាមនោះដែរប៉ូលិសម្នាក់ផ្សេងនិយាយផ្ទាន់៖

-ទៅតាម ទៅរកកាប់អ្នកណាទេដឹង?

សម្ដីរបស់ប៉ូលិសរូបនេះហាក់ដូចជាមានឥទ្ធិពលណាស់អាចធ្វើឲ្យជនល្មើសទាំងពីរ ងើបមុខពោលប្រកែកព្រមៗគ្នាយ៉ាងរហ័ស៖

-អត់ទេ! អត់មានទេ!

ប៉ូលិសរូបនោះ ពោលសួរវិញភ្លាម៖

-អញ្ចឹងយកពូថៅម្នាក់មួយលួចចូលទៅផ្ទះគេដើម្បីអ្វី?

ជនល្មើសពីរនាក់នោះងើបមុខសម្លឹងមកក្រុមអ្នកសួរចម្លើយដោយទឹកមុខស្លេកស្លាំង ម្នាក់ក្នុងចំណោមនោះដែលមានវ័យចាស់ជាងគូកនម្នាក់ទៀត ហើបមាត់តបដាច់ៗ៖

-ទៅ...ទៅ...កាប់ផើងផ្កាទេ! មិនមែនយកទៅកាប់អ្នកណាឡើយ!

វិទូយល់ថាអត់ទំនងទៅហើយដែលកណ្ដាលយប់បែរជានាំគ្នាឡើងទៅរកកាប់ផើងផ្កាក្នុងផ្ទះអ្នកដទៃយ៉ាងនេះ ប៉ុន្តែអ្នកមិនទាន់ហើបមាត់ពោលសួរថាយ៉ាងណាផង ប៉ូលិសផ្សេងម្នាក់ទៀត លាន់មាត់មុនម្ដង៖

-សុខៗម៉េចក៏ឡើងទៅរកកាប់ផើងផ្កា? និយាយឲ្យច្បាស់មកមើល៍!

ជនល្មើសម្នាក់ទៀតដែលមានវ័យក្មេងជាងគូកនខ្លួនបន្តិចជៀងភ្នែកសម្លឹងទៅគូកនខ្លួនដោយទឹកមុខរបៀបភិតភ័យ ប៉ុន្តែទាំងពីរនាក់គេមិនមានហើបមាត់ឆ្លើយតបជាមួយនឹងសំណួររបស់ប៉ូលិសសោះ ប៉ូលិសម្នាក់ដែលជាម្ចាស់សំណួរនោះទំនងជាមិនស្រួលចិត្តចំពោះអាកប្បកិរិយារបស់ជនល្មើសពីរនាក់នេះសោះ គាត់លើកដៃទះតុផាំង ទាំងដំឡើងសំឡេងទៅកាន់គេទាំងពីរ៖

-ពួកឯងឮគេសួរទេ? សុខៗម៉េចទៅកាប់បំផ្លាញផើងផ្កាគេ? មិនឆ្លើយចង់ត្រូវមែនទេ?

ភាគទី១៧

ពីរនាក់នោះឈ្ងោកមុខពីក្រោមសំឡេងខ្លាំងៗរបស់ប៉ូលិសដែលកំពុងសួរមកកាន់ខ្លួន វិទូសម្លឹងអាការរបស់គេទាំងពីរដែលកំពុងភិតភ័យ អ្នកកំលោះនឹកដល់មធ្យោបាយមួយ ក៏ហើបមាត់ពោលទៅកាន់ពួកគេភ្លាម៖

-ឯងកាន់ពូថៅនៅនឹងដៃឡើងផ្ទះគេម្ដងហើយម្ដងទៀតបែបនេះ ច្បាស់ជាមិនត្រឹមបំផ្លាញផើងផ្កានោះទេ មុខជាមានលាក់លៀមបំណងអាក្រក់អីផ្សេងទៀតហើយ!

ជនម្នាក់ក្នុងចំណោមជនល្មើសទាំងពីរដែលមានវ័យចំណាស់ជាងគូកនខ្លួនបន្តិច ឆ្លើយតបនឹងវិទូរដាក់រដុប៖

-អត់ អត់ទេ ខ្ញុំទើបតែឡើងទៅលើកទីមួយទេតើ!

វិទូសម្លឹងបុរសម្នាស់ចម្លើយនោះមិនព្រិច ហាក់ដូចជាចង់ដឹងថា តើម្នាក់នោះឆ្លើយមកនូវពាក្យពិតឬក៏មិនមែន ប៉ុន្តែគ្រាន់តែឃើញគ្រាប់ភ្នែកគេដែលក្រឡេបក្រឡាប់មិនឈប់នោះក៏អាចស្មានដឹងថា គេកំពុងមានបញ្ហាលាក់លៀម ឆ្លើយនូវចម្លើយមិនពិតដែរ! វិទូបញ្ចេញទឹកមុខស្មើធេងពោលសង្កត់ពាក្យធ្ងន់ៗជាងមុន៖

-កុហក! កាលពីប្រមាណមួយខែមុននេះ ឯងបានលួចឡើងទៅម្តងរួចហើយ កាលយប់នោះម្ចាស់ផ្ទះគេទាន់ ដូច្នេះហើយទើបយប់មិញនេះពួកឯងនាំគ្នាលួចឡើងទៅម្តងទៀត!

ជនល្មើសរូបនេះនៅតែព្យាយាមគ្រវីក្បាលពោលប្រកែក៖

-អត់មានទេ!

វិទូសម្លឹងឃើញមុខម្នាក់នោះ ក៏អាចកាត់យល់ថាគេកំពុងជ្រួលច្រាល់ក្នុងចិត្តដែរ ទោះបីជាអ្នកកំលោះមិនហ៊ានប្រាកដក្នុងចិត្តថាពីរនាក់នេះនិងពីរនាក់ដែលភីណានិយាយថាបានឃើញកាន់ពូថៅឈរឯរានហាលបន្ទប់វត្ថុបុរាណយប់មានភ្លៀងធំនោះ គឺជាមនុស្សដដែលឬក៏មិនមែនក៏ដោយ ប៉ុន្តែសភាពសង្ស័យយ៉ាងមោះមុតកំពុងដុតរោលក្នុងចិត្តអ្នកកំលោះរួចស្រេចទៅហើយ អ្នកដៀងភ្នែកសម្លឹងទៅជនល្មើសដែលមានវ័យក្មេងនោះម្តង អ្នកឃើញជននោះមានឫកពារញ៉ើរញ៉័រ ហាក់ដូចជាកំពុងស្ថិតក្នុងសភាពភ័យខ្លាចខ្លាំងណាស់ អ្នកដឹងថាចំណុចខ្សោយរបស់ម្នាក់នេះ គឺស្ថិតនៅត្រង់ភាពឆាប់តក់ស្លុតនេះឯង គិតឃើញដូច្នេះហើយទើបអ្នកកំលោះបំបែរទិសដើរចូលក្បែរជនល្មើសវ័យក្មេងនោះម្តង ដោយពោលបណ្តើរសម្លឹងមុខជនល្មើសរូបនោះយ៉ាងមុតបណ្តើរ៖

-ពីរនាក់ឯងតាមមើលមិនទាន់បានដឹងនៅឡើយទេ គឺថានិយាយកុហកមិនព្រមសារភាពនៅមុខប៉ូលិស ទោសនោះវារឹតតែធ្ងន់ទៅទៀត ពួកឯងនៅរឹងដល់ពេលណា? ពេលយើងអញ្ជើញម្ចាស់ផ្ទះនោះមកធ្វើសាក្សី គេចង្អុលមុខពីរនាក់ឯងនោះ ឯងចង់សារភាពមុខជាហួសពេលហើយ!

ដូចការគិតឃើញរបស់វិទូមែន ពេលដែលនាយស្មើរតែមិនទាន់បានបញ្ចប់ប្រយោគស្រួលបួលផង ក៏ស្រាប់តែពួជនល្មើសវ័យក្មេងនោះងើបមុខបញ្ចេញសំឡេងឆ្លើយតបមកវិញភ្លាម៖

-ខ្ញុំ...ខ្ញុំ សារភាព ខ្ញុំបានលួចឡើងផ្ទះនោះពីរដងហើយមែន តែ តែ គឺគាត់នេះអ្នកបបួលខ្ញុំមកទេ ខ្ញុំមិនដឹងអីទេ គាត់និយាយថាមកតាមគាត់នឹងបានលុយ ខ្ញុំ...ខ្ញុំក៏ធ្វើតាមគាត់ទៅ ដោះលែងខ្ញុំទៅ ខ្ញុំមិនដឹងអីទេ!

វិទូសម្លឹងមុខជននោះដោយពិនិត្យពិច័យ អ្នកពោលមួយៗសួរបន្ថែម៖

-គាត់ប្រាប់ឯងឲ្យមកតាមគាត់នឹងបានលុយ ចុះឯងមានឆ្ងល់ទេ ថាធ្វើម៉េចទើបបានលុយ? ឯងមានឆ្ងល់ថាម៉េចក៏គាត់ឲ្យឯងកាន់ពូថៅដែរទេ? ណាមួយលួចឡើងផ្ទះគេទាំងយប់អធ្រាត្រទៀត ឯងមានសង្ស័យថាគាត់នាំឯងទៅឲ្យសម្លាប់មនុស្សទេ?

ជនល្មើសវ័យក្មេងនោះប្រកបដោយទឹកមុខស្លេកស្លាំង មើលមុខគូកនខ្លួនបន្តិច ទើបងាកមកតបជាមួយវិទូ៖

-បាទ ខ្ញុំ ខ្ញុំសួរគាត់ដែរ ហើយក៏មិនមែនទៅសម្លាប់មនុស្សដែរ!

វិទូបង្ហាញភាពហួសចិត្ត ល្មមពេលនោះដែរប៉ូលិសម្នាក់ផ្សេងលូកមាត់ពោលម្តង៖

-មិនមែនទៅសម្លាប់មនុស្ស ហើយក៏មិនមែនទៅលួចឆក់ អញ្ចឹងឡើងផ្ទះគេទាំងយប់ធ្វើអ្វី? បានលុយតាមវិធីណា?

ជនល្មើសរូបនោះ សម្លឹងមុខប៉ូលិសម្តងម្នាក់ដោយទឹកមុខស្លេកស្លាំង គេឆ្លើយតបវិញអាក់ៗ៖

-គាត់ថា ទៅ ទៅ កាប់ផើងផ្កា ផ្ទះនោះយកអីវ៉ាន់របស់មានតម្លៃដាក់ក្នុងផើងផ្កានោះ គាត់ប្រាប់ខ្ញុំអញ្ចឹង!

ប៉ូលិសម្នាក់ផ្សេងសើចខឹករបៀបហួសចិត្ត គេពោលសួរវិញភ្លាម៖

-ចង់និយាយថា ទៅជីករកកំណប់ក្នុងនេះមែនទេ?

ជនល្មើសវ័យក្មេងតបវិញដោយអាការខ្លបខ្លាច៖

-គាត់ប្រាប់ខ្ញុំអញ្ចឹងមែន ខ្ញុំក៏មិនដឹងថាក្នុងនោះមានរបស់មានតម្លៃឬអត់ទេ ប៉ុន្តែខ្ញុំចេះតែមកតាមគាត់បបួលទៅក្រែងលោបានលុយចាយ!

វិទូសម្លឹងមកកាន់ជនល្មើសវ័យចំណាស់វិញម្តង អ្នកលាន់មាត់ពោលសួរយឺតៗច្បាស់ៗទៅកាន់គាត់នោះ៖

-ម៉េចក៏ឯងដឹងថា ក្នុងនោះមានរបស់មានតម្លៃ?

បុរសចំណាស់ដែលជាជនល្មើសនោះ តបមកកាន់អ្នកកំលោះវិញយ៉ាងកំបុត៖

-ឮគេថា!

វិទូធ្លាប់ជួបធ្លាប់ស្គាល់មនុស្សធុននេះច្រើនលើកមកហើយ ហើយអ្នកក៏ដឹងថាជាមួយនឹងជនរបៀបនេះគួរធ្វើការទៅតាមវិធីណាហើយដែរ អ្នកពោលសាជាថ្មីដោយទឹកមុខស្មើធេងទៅកាន់ជនល្មើស៖

-ឯងមិនប្រាប់តាមត្រង់ក៏មិនអីដែរ ប៉ុន្តែ ឯងលួចចូលផ្ទះគេគ្មានការអនុញ្ញាតទាំងយប់ងងឹតគឺខុសស្រេចទៅហើយ ឯងតោងទទួលការព្រមានខ្លះទើបបាន!

អ្នកកំលោះងាកទៅរកគូកនខ្លួនដោយធ្វើជាពោលប្រាប់៖

-នែ៎ សម្លាញ់ម្នាក់នេះមាត់រឹងណាស់ មិនចូលចិត្តធ្វើការជាមួយប៉ូលិសតាមសម្រួលទេ ឯងកុំយោគយល់ឲ្យសោះ ឲ្យមេរៀនឲ្យធ្ងន់បន្តិចទៅរួចហើយ អនុញ្ញាតឲ្យពួកកាសែតចូលថតយកទៅចុះផ្សាយលេងផង!

សម្តីរបស់វិទូហាក់ដូចជាបានធ្វើឲ្យជនល្មើសរូបនោះមានអាការខ្លបខ្លាចខ្លះដែរ អញ្ចឹងហើយទើបភ្លាមនោះ គេឮគាត់នោះពោលឡើងយ៉ាងរហ័ស៖

-ចង់ ចង់ ធ្វើយ៉ាងម៉េច? ប៉ូលិសចង់ធ្វើបាបគេតាមចិត្តអញ្ចឹង?

វិទូសម្លឹងមុខជននោះដោយញញឹមស្ងួត៖

-អត់មធ្យោបាយណាក្រៅពីនេះទេ នរណាប្រើឲ្យឯងធ្វើខុសធ្វើអី? ប៉ុន្តែ បើឯងព្រមធ្វើការជាមួយប៉ូលិសតាមសម្រួល នោះគឺជាករណីផ្សេងវិញ!

អ្នកកំលោះលួចសម្លឹងមើលប្រតិកម្មរបស់ជននោះ អ្នកកំលោះឃើញគាត់នេះឈ្ងោកមុខទំនងសញ្ជឹងគិត អ្នកនៅស្ងៀមរង់ចាំមើលតទៅទៀត ដោយគិតថាម្នាក់នេះកំពុងតែប្រប្រូកប្របល់

ចិត្តដោយក្តីភ័យខ្លាចខ្លាំងណាស់ហើយ។ ការគិតរបស់វិទូមិនខុសមែន ភ្លាមនេះជនល្មើសរូបនោះ ងើបមុខសាជាថ្មី ពោលសួរមកកាន់អ្នកកំលោះ៖

-បើខ្ញុំសារភាពតាមត្រង់ ពួកលោកដោះលែងខ្ញុំអ្ហេស៎?

អ្នកកំលោះវិទូឆ្លើយតបយ៉ាងរួសរាន់៖

-ឆាប់និយាយទៅ!

ជនល្មើសរូបនោះឆ្លើយតបមួយៗដោយជ្រប់មុខដដែល៖

-ខ្ញុំឡើងទៅលួចកាប់ផើងផ្កានោះ គឺដើម្បីរកខ្សែកមួយខ្សែទេ!

វិទូសម្លឹងជននោះមិនព្រិច ដោយបន្លឺវាចាសួរភ្លាម៖

-ខ្សែក? កន្លែងនោះមានសុទ្ធតែដីទេតើ! មានខ្សែកពីណាមក?

ជនល្មើសរូបនោះ មិនទាន់ឆ្លើយតបនឹងវិទូទេ ភ្លាមនោះគូកនជនល្មើសដែលមានវ័យក្មេងបន្តិចនោះឆ្លើយតបជំនួស៖

-គឺមានមែន មានខ្សែកពេជ្រ ក្នុងនោះ!

វិទូងៀងភ្នែកមើលមកជនល្មើសវ័យក្មេងនេះម្តង អ្នកពោលសួរទៅកាន់ជននោះ៖

-ម៉េចក៏ឯងដឹង?

ជនរូបនោះឈ្ងោកមុខវិញភ្លាមកាលបើឮវិទូដំឡើងសំឡេងសួរ គេឆ្លើយតបមកវិញរដាក់រដុបទាំងដៃចង្អុលទៅគូកនរបស់ខ្លួន៖

-គាត់ គាត់ ប្រាប់ខ្ញុំ គាត់ប្រាប់ខ្ញុំថាមានខ្សែកពេជ្រក្នុងនោះ!

អ្នកកំលោះវិទូដកក្រសែភ្នែកចេញពីជនល្មើសរូបនោះ ដោយងាកមកមើលជនល្មើសដែលមានវ័យចំណាស់ម្តង អ្នកពោលសួរច្បាស់ៗ៖

-ប្រមាណមួយខែមុននេះ ឯងមានលួចទៅរកកាប់ផើងផ្កានោះម្តងរួចមកហើយមែនទេ?

ម្តងនេះ ជនល្មើសវ័យចំណាស់ទំនងជាលែងហ៊ានប្រកែកទៀតហើយ គាត់ពោលតបដោយជ្រប់មុខជាប់៖

-មែន!

វិទូជ្រួញចិញ្ចើមដោយពិភាល់ក្នុងចិត្ត ដូចនេះសម្តីដែលភីណានិយាយថាយប់នោះ នាងនិងបងថ្លៃបានប្រទះឃើញបុរសប្លែកមុខពីរនាក់លើដៃមានកាន់ពូថៅម្នាក់មួយឯរានហាលបន្ទប់ដាក់វត្ថុបុរាណ គឺជាការពិតណាស់ វិទូរិះគិតម្តងហើយម្តងទៀតដោយមិនដាច់ស្រេច បើយ៉ាងនោះមែន តើរឿងដែលនាងក្រមុំប្រាប់ថា កាលណោះព្រោះតែរត់គេចដោយក្តីតក់ស្លុត បងថ្លៃនាងបានទាក់ជើងដួលពីលើទៅជាន់ខាងក្រោមដាច់ខ្យល់ស្លាប់នោះ គឺជាការពិតទេដឹង?

គិតយ៉ាងនេះបណ្តើរអ្នកងាកមករកជនល្មើសវ័យចំណាស់សាជាថ្មីដោយសួរបន្ថែម៖

-កាលយប់នោះ ឯងទាំងពីរឡើងទៅមិនទាន់បានកាប់ផង ក៏ត្រូវម្ចាស់ផ្ទះ ឡើងមកឃើញទាន់មែនទេ?

ជននោះឈ្ងោកមុខជាប់ ប៉ុន្តែមាត់ក៏នៅតែតបវិញ៖

-មែន!

វិទូពោលសួរបន្ថែមយ៉ាងបន្ទាន់៖

-ក្រោយពេលម្ចាស់ផ្ទះឡើងមកទាន់ហើយ តើនៅមានរឿងអីទៀត?

ជនល្មើសរូបនោះរិះគិតបន្តិចទើបឆ្លើយ៖

-គ្មានរឿងអីទៀតទេ ខ្ញុំនាំគ្នារត់ចុះក្រោមតាមបំពង់ខាងមុខរានហាលយ៉ាងរហ័សទៅ!

វិទូសម្លឹងជននោះដោយទឹកមុខមិនសប្បាយចិត្ត អ្នកងាកមករកគូកនជនល្មើសដែលមានវ័យក្មេងអ្នកដឹងថាជននេះសម្បូរគំនិតកំសាកណាស់ ដូច្នេះហើយពេលសួរចម្លើយទំនងជាឆាប់បានការជាង អ្នកពោលសួរខ្លាំងទៅកាន់ជនល្មើសដែលមានវ័យក្មេងនោះ៖

-នែ៎ ឯងនៅចាំព្រឹត្តិការណ៍ទាំងប៉ុន្មាននាយប់នោះដែរទេ ឆាប់ឆ្លើយភ្លាមមក!

ជនល្មើសវ័យក្មេងងើបមុខដែលសស្លេតសស្លក់សម្លឹងមកវិទូបណ្តើរពោលតបបណ្តើរ៖

-បាទ!...ចាំ...កាល... កាលយប់នោះ ខ្ញុំពីរនាក់ឡើងទៅដល់ប្រុងកាប់ទៅហើយ ក៏ស្រាប់តែម្ចាស់ផ្ទះគេឡើងមកទាន់ ប៉ុន្តែ សុទ្ធតែជាស្រីទេ ពេលឃើញពួកខ្ញុំភ្លាមស្រីពីរនាក់នោះស្រែកខ្លាំងៗរត់ចូលទៅក្នុងផ្ទះវិញយ៉ាងលឿន ឯខ្ញុំពីរនាក់ ក៏នាំគ្នារត់គេចភ្លាមដែរ ខ្លាចស្រីពីរនាក់នោះទៅហៅគេមកទាន់។

វិទូសួរវិញបន្ថែមភ្លាមយ៉ាងរហ័ស៖

-មានតែប៉ុណ្ណឹងទេអ្ហេស៎? ឯងមានឮអ្វីផ្សេងទៀតទេ ក្រោយពីស្រីពីរនាក់នោះ នាំគ្នារត់ទៅ?

អ្នកកំលោះយើងពោលសួរបណ្តើរ តាមដានសម្លឹងផ្ទៃមុខជនល្មើសរូបនោះបណ្តើរ អ្នកឃើញជននោះធ្វើភ្នែកស្លឹរបៀបដូចជាកំពុងសញ្ជឹងគិត ខណៈនោះគេលាន់មាត់ឆ្លើយតបមកកាន់វិទូ៖

-អត់ទេ! ខ្ញុំអត់មានពេលរវល់ទេ!

អ្នកកំលោះកំពុងលង់គំនិតទៅក្នុងការត្រិះរិះ គាប់ជួនពេលនោះដែរ ប៉ូលិសផ្សេងម្នាក់ទៀតពោលសួរទៅកាន់នោះដែរ ប៉ូលិសផ្សេងម្នាក់ទៀតពោលសួរទៅកាន់ជនល្មើសវ័យចំណាស់៖

-នែ៎ ម៉េចក៏ឯង ដឹងថាក្នុងផើងដាំផ្កានោះមានខ្សែកពេជ្រ ហើយឡើងទៅកាប់ផើងរក?

ជនរូបនោះតាមមើលកំពុងរិះគិតមិនដឹងថាគួរឆ្លើយយ៉ាងណានៅឡើយទេ ដូច្នេះហើយទើបគាត់ឈ្ងោកមុខជាប់មិនចេញស្តី ប៉ូលិសដដែលនោះលាន់មាត់និយាយបន្ថែម៖

-អ្ហ៎ូ! ក្រែងឯងលបឡើងទៅរកធ្វើបាបអ្នកណាទេដឹង ហើយមកយកលេសឆ្លើយថាឡើងទៅរកខ្សែកឯណាឯណោះទៅវិញ? គួរឲ្យសង្ស័យដែរ ខ្សែកឯណានៅក្នុងផើងផ្កានោះ?

ជនល្មើសរូបនោះ ត្រូវប៉ូលិសពោលបញ្ឆោតក៏ប្រញាប់ប្រញាល់ងើបមុខបដិសេធយ៉ាងរហ័ស៖

-ទេ! ខ្ញុំគ្មានរកទៅធ្វើបាបអ្នកណាទេ ខ្ញុំឡើងទៅរកកាប់ផើងរកខ្សែកមែន ក្នុងផើងនោះប្រាកដជាមានខ្សែកមែន! ពួកលោកជឿខ្ញុំចុះ!

ប៉ូលិសម្នាក់ទៀតបន្លឺសួរវិញភ្លាមដែរ៖

-អញ្ចឹងម៉េចក៏ឯងដឹងថា ក្នុងនោះមានខ្សែកពេជ្រ ហើយបបួលគ្នាឡើង ទៅកាប់បំផ្លាញជើងផ្ទះគេរកខ្សែក? បើឯងមិនឆាប់ប្រាប់ឲ្យច្បាស់លាស់ទេនោះ យើងនឹងគិតថាឯងលួចឡើងទៅផ្ទះគេទាំងយប់អធ្រាត្រ មានទាំងកាន់ពូថៅនៅនឹងដៃទៀត ថាទៅរកធ្វើបាបមនុស្សហើយ!

ជននោះមានឫកពាដូចជាភ័យខ្លាចណាស់ កាលបើឮសម្ដីប៉ូលិសស្ដីយ៉ាងដូច្នោះ គាត់តបវិញដោយភិតភ័យៈ

-អត់ទេ! ខ្ញុំមិនបានទៅធ្វើបាបអ្នកណាទេ ខ្ញុំយកពូថៅទៅកាប់ជើងទេ ខ្ញុំរកខ្សែក ខ្ញុំមិនចង់ធ្វើបាបអ្នកណាទាំងអស់។

វិទូដែលកំពុងតែសញ្ជឹងគិតក៏មាត់ពោលសួរភ្លាមៈ

-ឯងដឹងពីណាមក? ថាក្នុងនោះមានខ្សែកពេជ្រ? បើឯងមិននិយាយទេ គ្មានផ្លូវរួចខ្លួនទេ!

ជនល្មើសទំនងដូចជានឹងថាមិនអាចលាក់លៀមតទៅទៀតបានទេ ម្ល៉ោះហើយទើបគាត់ឆ្លើយតបតិចៗៈ

-ខ្ញុំដឹងតាំងពីបួនឆ្នាំមុនម្ល៉េះ?

សម្ដីរបស់គាត់នោះតិចៗក៏ពិតមែន ប៉ុន្ដែច្បាស់ណាស់ ពួកគេបើកភ្នែកមូលក្លុំសម្លឹងមករកជនល្មើសរូបនោះដោយក្ដីងឿងឆ្ងល់ដូចៗគ្នា វិទូបន្លឺសួរភ្លាមៈ

-មានន័យថាម៉េច? ឯងរៀបរាប់ឲ្យច្បាស់មកមើល៍?

ជនល្មើសរូបនោះហើបមាត់វាចាតិចៗក្រោមការផ្ទៀងស្ដាប់យ៉ាងយកចិត្តទុកដាក់របស់ក្រុមអ្នកសួរចម្លើយៈ

-រឿងហេតុកន្លងទៅ៤ឆ្នាំជាងមកហើយ ដែលខ្ញុំដឹងថាមានខ្សែកពេជ្រកប់ទុកក្នុងជើងផ្កាផ្ទះធំពីរជាន់នោះ កាលណោះខ្ញុំជាអ្នកធ្វើបំពង់ទឹក ម្ចាស់ផ្ទះពីមុននោះ បានជួលខ្ញុំឲ្យមកធ្វើបំពង់ទឹកនៅផ្ទះគាត់ ថ្ងៃនោះខ្ញុំធ្វើបំពង់ទឹកនៅជាន់ខាងលើរួច ក៏ត្រឡប់ទៅផ្ទះវិញក្រោយពីទទួលលុយពីម្ចាស់ផ្ទះរួច ប៉ុន្ដែដល់ពាក់កណ្ដាលផ្លូវដឹងថាធ្វើភ្លេចពិលនៅផ្ទះនោះ អញ្ចឹងហើយទើបត្រឡប់ក្រោយទៅយកពិលវិញ ពេលនោះយប់ងងឹតហើយ ខ្ញុំចូលតាមទ្វារក្រោយរកជួបអ្នកបម្រើដើម្បីប្រាប់ថា សុំឡើងទៅយកពិល ប៉ុន្ដែ ពេលដែលខ្ញុំចូលទៅដល់បែរជាមិនមាន

ឃើញមនុស្សណាម្នាក់សោះ ណាមួយយប់ក៏កាន់តែជ្រៅទៀត ខ្ញុំគិតថាឡើងទៅយកពិលរួចចាកចេញភ្លាម ខ្ញុំក៏ចូលទៅក្នុងផ្ទះនោះទៅ។

ជនល្មើសនិយាយដល់ត្រឹមណេះ ក៏ស្រាប់តែប៉ូលិសម្នាក់លាន់មាត់របៀបហួសចិត្ត៖

-មនុស្សឯងនេះចំជាអស្ចារ្យណាស់! ម្ចាស់គេមិនដឹងផង ឯងចេះចូលផ្ទះគេដោយស្ងាត់ៗអញ្ចឹងទៅកើតដែរ?

ជនល្មើសរូបនេះឈ្ងោកមុខមិនចេញស្តី រំទូលាន់មាត់ពោលសួរ៖

-បន្ទាប់មកយ៉ាងម៉េចទៀត? ឯងឆាប់និយាយទៅ ជនល្មើសចាប់ផ្តើមពោលបន្តយឺតៗ៖

-ពេលចូលដល់ផ្ទះ ក៏គ្មានឃើញមនុស្សម្នាក់ណាសោះ ប៉ុន្តែខ្ញុំឃើញមានឈាមតក់ពេញលើឥដ្ឋពីមាត់បន្ទប់មួយរហូតដល់ជណ្តើរឡើងទៅជាន់ខាងលើ ខ្ញុំភ័យណាស់ គិតថាពេលខ្ញុំចេញអម្បាញ់មិញ ក្នុងផ្ទះកើតមានរឿងអីទេដឹង? ម៉េចក៏ស្ងាត់ច្រៀបហើយមានតក់ឈាមអញ្ចឹង?

ពួកប៉ូលិសងៀងភ្នែកមើលមុខគ្នាដោយក្តីសង្ស័យ ក្នុងខណៈនោះដែរជនល្មើសរូបនោះពោលបន្ត៖

-ក្នុងពេលនោះខ្ញុំភ័យណាស់ ចង់រត់ចេញក្រៅបន្តិចចង់ឡើងទៅខាងលើមើលបន្តិច ស្រាប់តែរំពេចនោះ ខ្ញុំឮសូរមនុស្សស្រែកហៅឲ្យជួយ "ជួយផងៗ" ខ្ញុំឮភ្លាមក៏ស្គាល់ថាជាសំឡេងនាងក្រមុំអ្នកបម្រើក្នុងផ្ទះនោះ ហើយសំឡេងនោះក៏ច្បាស់ជាឮមកពីជាន់ខាងលើ ភ្លាមនោះខ្ញុំរត់ឡើងទៅយ៉ាងរហ័ស កាន់តែឡើងទៅរឹតតែឮសូរនាងស្រែកឲ្យជួយនោះច្បាស់ឡើង ហើយសំឡេងនោះកំពុងឮចេញមកពីបន្ទប់ខាងស្តាំដៃ ជាប់បន្ទប់ដែលខ្ញុំចូលទៅធ្វើបំពង់ទឹកកាលពីល្ងាចនោះឯង ខ្ញុំភ័យខ្លាំងណាស់ បន្ទាប់មកមានឮសូរសំឡេងដូចជាមានអ្នកណាកំពុងវាយអ្នកណាម្នាក់ ដោយដំបងឬបំពង់ដែកឮសូរខ្លាំងៗ ឯសំឡេងស្រែកឲ្យជួយរបស់អ្នកបម្រើនោះក៏លែងឮទៀត ខ្ញុំឃើញមានឈាមតក់ពីមាត់ជណ្តើររហូតដល់បន្ទប់ខាងស្តាំនោះ ខ្ញុំនឹកភ្លាមថា ក្នុងបន្ទប់នោះច្បាស់ជាមានរឿងមិនធម្មតាអ្វីមួយកើតឡើងហើយ ប៉ុន្តែខ្ញុំនៅមិនហ៊ានចូលទៅមើលនៅឡើយទេ នៅឈរទីទើរៗអស់បន្តិចទើបសម្រេចចិត្តថា ចូលទៅក្នុងបន្ទប់ដែលខ្ញុំ

ធ្វើបំពង់ទឹកកាលពីល្ងាចនោះ រួចលបមើលទៅបន្ទប់ខាងស្តាំដៃតាមរានហាលធ្វើអញ្ចឹងច្បាស់ជានឹងអាចដឹងថា តើមានរឿងអ្វីកំពុងកើតឡើងក្នុងបន្ទប់នោះហើយ។

និយាយដល់ត្រង់ណេះ ជនល្មើសបង្អង់ឈប់បន្តិចក្នុងពេលបន្ទាន់នោះដែរ វិទូពោលសួរភ្លាម៖

-ចុះឯងបានឃើញអ្វីខ្លះ?

ជនល្មើសរូបនោះរវើ្នករបៀបរកនឹក ភ្លាមនោះគាត់ឆ្លើយតបមកវិញមួយៗ៖

-កាលណោះខ្ញុំចូលទៅក្នុងបន្ទប់ក្បែរនោះរួចបម្រុងចេញទៅរានហាលខាងមុខដើម្បីនឹងលបមើលទៅកាន់បន្ទប់ខាងស្តាំនោះហើយ ប៉ុន្តែឈានដល់រានហាលខាងមុខបន្ទប់ខាងស្តាំនោះហើយ ប៉ុន្តែឈានដល់រានហាលខាងមុខបន្ទប់បានមួយជំហានប៉ុណ្ណោះ ខ្ញុំត្រូវភ្ញាក់យ៉ាងខ្លាំងត្បិតអីពីបន្ទប់ដែលខ្ញុំកំពុងឈរនេះសម្លឹងទៅបន្ទប់ខាងស្តាំដៃ ខ្ញុំមើលឃើញច្បាស់ណាស់ថាប្តីប្រពន្ធម្ចាស់ផ្ទះកំពុងកាន់ដំបងវាយសំពងទៅលើមនុស្សម្នាក់ដែលកំពុងប្រឡាក់ឈាមជោកខ្លួនដេកនៅផ្ទាល់នឹងឥដ្ឋ ប៉ុន្តែពេលដែលប្តីប្រពន្ធម្ចាស់ផ្ទះកំពុងវាយវាត់ឥតសំចៃដៃនោះ រាងកាយអ្នករបួសនៅកម្រើកតិចៗនៅឡើយ ខ្ញុំភ័យស្លន់ស្លោណាស់ តាមពិតមិនមែនពីរនាក់ម្ចាស់ផ្ទះនេះជួបរឿងហេតុអាក្រក់ឯណា គឺពីរនាក់គាត់កំពុងសម្លាប់មនុស្សច្បាស់ណាស់ ក្នុងពេលដែលខ្ញុំកំពុងស្លន់ស្លោ ខ្ញុំឃើញរាងកាយដែលប្រឡាក់ឈាមនោះនៅស្ងៀមស្ងួតលែងកម្រើក ខ្ញុំគិតថាច្បាស់ជាត្រូវគេវាយរហូតទាល់តែដាច់ខ្យល់ស្លាប់ហើយ ខ្ញុំយល់ថាពេលនេះបើឃាតកពីរនាក់នោះវាដឹងថាខ្ញុំត្រឡប់មកវិញហើយលបឃើញហេតុការណ៍របស់វា ខ្ញុំច្បាស់ជាជួបរឿងធំមិនខាន គិតហើយខ្ញុំនឹកភ័យណាស់ប៉ុន្តែក៏នៅប្រឹងសម្លឹងទៅទីនេះមិនហ៊ានដកភ្នែកដែរ ភ្លាមនោះខ្ញុំឃើញឃាតកពីរនាក់ប្តីប្រពន្ធនាំគ្នាជីកដីចេញពីផើងផ្កានោះ រួចបន្ទាប់មកទើបនាំគ្នាលើកអ្នកស្លាប់ទម្លាក់ទៅក្នុងផើងនោះ គឺពេលនោះហើយដែលខ្ញុំមើលស្គាល់ថាអ្នកដែលត្រូវពីរនាក់ប្តីប្រពន្ធនោះវាយរហូតដល់ស្លាប់ គឺនាងអ្នកបម្រើដែលទើបតែបើកទ្វារឲ្យខ្ញុំចេញទៅផ្ទះកាលពីមុននេះប៉ុន្មានម៉ោងនោះឯង។

វិទូជ្រួញចិញ្ចើមសម្លឹងមកជនល្មើសដែលកំពុងរៀបរាប់ ភ្លាមនោះប៉ូលិសម្នាក់ផ្សេងលូកមាត់ពោលសួរមកភ្លាម៖

-ឯងនិយាយផ្តេសផ្តាសទេដឹង? ម៉េចនឹងមានរឿងអញ្ចឹងកើតឡើង!

ជនល្មើសរូបនោះងើបមុខសម្លឹងប៉ូលិសអម្បាញ់មិញ គេពោលដោយទឹកមុខមិនសប្បាយចិត្ត ៖

-ពួកលោកឲ្យខ្ញុំនិយាយ ប៉ុន្តែបើមិនព្រមជឿ ឲ្យខ្ញុំនិយាយធ្វើអ្វី?

ប៉ូលិសរូបនោះងក់ក្បាលផ្ងក់ៗ តបដោយទឹកមុខស្មើ៖

-បាន! និយាយតទៅទៀតទៅ! បើឯងហ៊ានពោលបំផ្លើសផ្ដេសផ្ដាសស្រេចនឹងចិត្តនោះ កុំថាមិនបានប្រាប់ណ៎ា!

វិទូក៏លូកមាត់ពោលបន្ថែម៖

-និយាយតទៅទៀតភ្លាមទៅ! ក្នុងផើងនោះមានមនុស្សស្លាប់មែនអ្ហេស៎?

ជនល្មើសរូបនោះឱនមុខឆ្លើយយឺតៗ៖

-ត្រូវហើយ! ពីរនាក់ប្ដីប្រពន្ធទម្លាក់ស្រីបម្រើទៅក្នុងនោះខ្ញុំឃើញផ្ទាល់ភ្នែក ហើយពេលនោះខ្ញុំថែមទាំងឮអ្នកស្រីនោះស្រែកប្រាប់ប្ដីគាត់ថា ធ្វើជ្រុះខ្សែកទៅជាមួយសាកសពក្នុងផើងនោះហើយ ប៉ុន្តែប្ដីគាត់ឆ្លើយរបៀបភ័យស្លន់ថា"បាត់ក៏បាត់ទៅ ខ្សែកមួយខ្សែនោះ" ហើយឲ្យប្រពន្ធគាត់ប្រញាប់គ្របដីពីលើសាកសពវិញឲ្យបានឆាប់ ខ្ញុំឈរលបមើលពីរនាក់នោះនាំគ្នាកប់អ្នកស្លាប់ក្នុងផើងនោះ រហូតដល់យូរបន្តិចដែរទើបខ្ញុំរត់ចេញពីផ្ទះនោះវិញ សូម្បីពិលក៏មិនបានយកមកតាមផង!

ភាគទី១៨

ប៉ូលិសម្នាក់ទៀត លាន់មាត់របៀបយល់សាច់រឿង៖

-តាមពិត គឺឯងនៅនឹកចង់បានខ្សែកដែលឃាតកធ្វើជ្រុះនោះសោះ អញ្ចឹងហើយទើបឡើងទៅ កាប់ផើងផ្កាម្ដងជាពីរដង!

ជនល្មើសមិនទាន់ឆ្លើយតបថាយ៉ាងណាផង ប៉ូលិសផ្សេងម្នាក់ទៀត បន្លឺសួរម្ដង៖

-ចុះម៉េចក៏ ឯងដឹងថាខ្សែកនោះ គឺជាខ្សែកពេជ្រដ៏មានតម្លៃ?

ជនល្មើសរូបនោះឈ្ងោកមុខជាប់ ប៉ុន្តែមាត់នៅតែតប៖

-ព្រោះថាពេលកាយដីគ្របលើសាកសព អ្នកស្រីនោះនៅរអ៊ូមិនឈប់ថាស្ពាយខ្សែកពេជ្រមានតម្លៃនោះណាស់ អញ្ចឹងហើយទើបខ្ញុំដឹងថានោះជាប្រភេទខ្សែកដ៏មានតម្លៃ!